# មជ្ឈមណ្ឌលឯកសារកម្ពុជា

## របាយការណ៍

## ស្តីពីទីតាំងសម្លាប់និងមន្ទីរសន្តិសុខនៅស្រុកអូររាំងឪ ខេត្តកំពង់ចាម

## កាលពីថ្ងៃទី៨-១២ ខែសីហា ឆ្នាំ២០០១

ដោយ ផេង ពង្សរ៉ាស៊ី

ស្រុកអូររាំងឪ ជាស្រុកមួយស្ថិតនៅខាងជើងភាគខាងកើតខេត្តកំពង់ចាម និងស្ថិតក្នុងភូមិភាគបូព៌ានៃប្រទេស ។ កាលពីឆ្នាំមុនៗ ក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅធ្វើការស្រាវជ្រាវម្តងរួច ហើយនៅស្រុកអូររាំងឪលើទីតាំងមួយចំនួន ។ ប៉ុន្តែនៅមានទីតាំងមួយចំនួនទៀតដែលមិនបានចុះទៅដល់ដោយ សារមានការលំបាកក្នុងការធ្វើដំណើរ និងតំបន់អសន្តិសុខ ។ រហូតមកដល់ខែសីហា ឆ្នាំ២០០១នេះ ក្រុម យើងបានចុះទៅធ្វើការសិក្សាស្រាវជ្រាវបន្តទៅលើ ទីតាំងមួយចំនួនដែលនៅសេសសល់នោះ ។ តាមតារាងស្ថិតិ របស់ការិយាល័យវប្បធម៌ និង ព័ត៌មានស្រុកអូររាំងឪបានឲ្យដឹងថានៅមានទីតាំងចំនួន១៣កន្លែងទៀតដែលមិន ទាន់សិក្សា ។ នេះជាគោល បំណងក្នុងការចុះធ្វើការស្រាវជ្រាវនៃក្រុមស្រាវជ្រាវធ្វើដែនទីរណ្តៅសាកសព ។ ទីតាំងទាំង១៣នោះគឺៈ

### ឃុំព្រះធាតុ

១) អណ្តូងដង្កោស៊ាន — លេខកូតភូមិសាស្រ្តៈ ០៣១១០៤

រយៈកំពស់ **(N) 11º 50' 58:19"** — រយៈទទឹងៈ **(E) 105º 29' 38:80"**

ដង្កោស៊ាន ជាដង្កោម្នាក់ដែលល្បីឈ្មោះកាលពីទសវត្តន៍ទី៦០ ថាជាអ្នកដែលមានដីធ្លីច្រើនរាប់ហិកតា និងមានកូនឈ្នួលស្ទើរតែពេញមួយភូមិ ។ បច្ចុប្បន្នកូនឈ្នួលរបស់គាត់មួយចំនួនបានស្លាប់កាលពីជំនាន់ប៉ុលពតនិងមួយចំនួនទៀតបានក្លាយជាម្ចាស់ដីដែលជាអតីតដីរបស់ដង្កោស៊ាន ។ ដង្កោស៊ានបានស្លាប់ដោយជម្ងឺកាលពីឆ្នាំ១៩៨៣ ។ ចំណែកកូនរបស់គាត់ដែលសព្វថ្ងៃនៅសល់ពីរនាក់នោះ ស្ទើរតែរកអន្ករប្រកឆ្នាំងមិនបាន ឯផ្ទះ វិញមើលពីមុខធ្លុះទៅក្រោយ ។ ដីស្រែចំការទាំងឡាយដែលជារបស់ឪពុកកាលពីមុន ត្រូវរដ្ឋដកហូតអស់ នៅ សល់តែដីមួយឡូប៉ុណ្ណោះសម្រាប់ដាំដំណាំ ។ អតីតផ្ទះរបស់ដង្កោស៊ាន ត្រូវរើបអូសយកធ្វើជាកន្លែងធ្វើការ និង ធ្វើសន្តិសុខបណ្តោះអាសន្នរបស់ខ្មែរក្រហម ហើយដីមួយឡូដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីផ្ទះសន្តិសុខនោះត្រូវ បានជ្រើសរើសយកធ្វើជាកន្លែងសម្លាប់មនុស្សចោល ព្រោះមានអណ្តូងទឹកចំនួនពីរធ្វើជារណ្តៅស្រាប់ ។ លោក ពូស៊ាន សុខា ជាកូន

Documentation Center of Cambodia
Searching for the Truth
ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌
DC-Cam ◆ 66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
Tel: (855-23) 211-875 ◆ Fax: (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

ប្រុសរបស់ដង្ហោស៊ាន អាយុ៥៤ឆ្នាំ ទីលំនៅសព្វថ្ងៃនៅភូមិថ្នល់កែង ឃុំព្រះធាតុ ស្រុក អូរាំងឪ ខេត្តកំពង់ចាមបានរៀបរាប់ប្រាប់យើងអំពីការសម្លាប់មនុស្សនៅក្នុងអណ្តូងទឹកឪពុករបស់គាត់ថា មានអណ្តូងទឹកធំៗចំនួនពីរបានក្លាយទៅជាអណ្តូងដាក់សាកសព ។ ចម្ងាយពីអណ្តូងមួយទៅអណ្តូងមួយមានចម្ងាយ ប្រហែលជាង៣០ម៉ែត្រប៉ុណ្ណោះ ។ លោកពូស៊ាន សុខា បានបង្ហើបឲ្យដឹងថាមានវត្តអារ៉ាមមួយនៅក្នុងភូមិរបស់ គាត់ ឈ្មោះវត្តព្រះធាតុ ស្ថិតក្នុងភូមិព្រះធាតុ ឃុំព្រះធាតុ ស្រុកអូរាំងឪ ត្រូវបានបំផ្លាញដោយពួកខ្មែរ ក្រហម ហើយយកទីតាំងវត្តនោះធ្វើជាជម្រកបណ្តោះអាសន្នសម្រាប់ដាក់ អ្នកជម្លៀស៧៥មកពីភ្នំពេញ ។ កុដ្ឋនានាក្នុងវត្តត្រូវបានរុះរើមកធ្វើជារោងបាយសម្រាប់អ្នកជម្លៀស ។ ប្រជាជនមកពីភូមិត្រពាំងនាង និងភូមិ ថ្នល់កែង ត្រូវបានបង្ខំឲ្យទៅរុះរើព្រះវិហារវត្តព្រះធាតុ ។ លោក អ៊ំ ទុយ ជាប្រជាជនរស់នៅភូមិថ្នល់កែង បាន និយាយថា គាត់ធ្លាប់បានចូលរួមក្នុងការរុះរើកុដ្ឋនៅក្នុងវត្តព្រះធាតុនេះ ។ សៀវភៅធម៌ និងសាស្ត្រាស្លឹករឹត ត្រូវបានដុតបំផ្លាញអស់ ។ មានព្រះសង្ឃជាច្រើនត្រូវបានផ្សឹកក្រោមការគាបសង្កត់ ។ ព្រះសង្ឃព្រះនាម រស់ ហេង សព្វថ្ងៃជាគ្រូសូត្រស្តាំនៅវត្តព្រះធាតុបានមានពុទ្ធដីការបញ្ជាក់ពីការផ្សឹកព្រះសង្ឃនៅវត្តព្រះធាតុថា«មានព្រះសង្ឃ ប្រហែលជាង២០អង្គត្រូវបានផ្សឹក គ្រាន់តែសឹកបណ្តោះគ្នាម្តងពីរម្តងបីម្តងមួយអញ្ចឹងទៅ ។ អាត្មាបានសឹកពីបួសនៅឆ្នាំ១៩៧៥ ខែអាសាធត្រូវនឹងថ្ងៃទី៧» ។ ព្រះតេជគុណបានមានពុទ្ធដីការបន្តថា «អាត្មាត្រូវតែសឹកព្រោះបើមិនដូច្នេះទេ នឹងអាចត្រូវទណ្ឌកម្ម» ។ មានព្រះសង្ឃមួយអង្គទៀតព្រះនាម អ៊ី ត្រូវបានពួកខ្មែរក្រហមចាប់សម្រាតស្បង់ជីពរចេញពីខ្លួនដោយសារព្រះសង្ឃអង្គនោះដាច់ខាតមិនព្រមសឹក ។ ប៉ុន្តែទីបញ្ចប់ការផ្សឹកនៅតែបានសម្រេច ដោយសារមានបទបញ្ជាមួយដែលដាក់មកគំរាមព្រះសង្ឃគ្រប់អង្គថា នឹងយកទៅដាក់គុក១-២ដែលជាគុករបស់ស្រុកអូរាំងឪ ។ កាលនោះមានឈ្មោះ តាពេជ្រ ឋានៈជាមេបញ្ជា ការកងទ័ពនៅភូមិភាគបូព៌ា ដែលដើរជាមួយ សោភឹម ជាអ្នកមកផ្សឹកព្រះសង្ឃ ។ ព្រះវិហារត្រូវបិទលែងឲ្យ មានការគោរពសាសនា និងការដុតធូបទានបន់ស្រន់នានា ។ ពេលថ្ងៃសីល ឬថ្ងៃបុណ្យទានម្តងៗតាមប្រពៃណី ប្រជាជនខ្លះបានលួចដុតធូបទាននៅតាមផ្ទះយ៉ាងលួចលាក់បំផុត ។ ការប្រជុំនឹងកើតមានឡើងនៅរៀងរាល់មួយ សប្តាហ៍ម្តងដែលមានគណៈឃុំ ឬគណៈសហករណ៍ ជាអ្នកបើកអង្គប្រជុំ ។ ទិសដៅក្នុងអង្គប្រជុំ គឺពង្រឹង សមត្ថភាព និងធ្វើឲ្យទាល់តែបាននូវផែនការស្រែមួយហិកតាទទួលផលស្រូវពី៣ទៅ៤តោន ។ ប្រជាជនម្នាក់ៗ ប្រឹងគ្មានពេលសម្រាក ពេលយប់មិនហ៊ានជជែកគ្នា ព្រោះអស់កម្លាំង និងម្យ៉ាងខ្លាចកងឈ្លបដែលតែងតែមក លួចស្តាប់ការសន្ទនាផ្សេងៗពីប្រជាជន ។ តួនាទីរបស់កងឈ្លបប្រចាំសហករណ៍នៅឃុំព្រះធាតុ ត្រូវបាន លោកពូ ស៊ាន សុខា និយាយប្រាប់ថា «ពេលថ្ងៃដេក និងពេលយប់ដើរស៊ើបការណ៍» ។ វត្តព្រះធាតុបាន ក្លាយជាទីលាន្ត

សម្រាប់សុ្គបប្រជាជន១៧មេសាចំនួនជាង១៥០គ្រួសារមកពីភ្នំពេញ និងកន្លែងផ្សេងទៀត។ លោកពូ ស្រ៊ុយ ប៊ុនសៀ អាយុ៥៩ឆ្នាំ សព្វថ្ងៃរស់នៅភូមិទួលញ្ញោ ឃុំព្រះធាតុបានអធិប្បាយប្រាប់ថា គាត់ត្រូវបានជម្លៀសចេញទៅនៅខេត្តកំពង់ធំកាលពីចុងឆ្នាំ១៩៧៨ ដោយពួកខ្មែរក្រហមខាងនិរតីចោទថា "ក្បាលយួន ខ្លួនខ្មែរ"។ លោកពូបានមានប្រសាសន៍បន្តថា នៅក្នុងវត្តព្រះធាតុមានប្រជាជនមកស្នាក់នៅ ច្រើនណាស់មានទាំងកូន ទាំងចៅដែលជម្លៀសមកពីភ្នំពេញ។ ការងាររបស់ពួកអ្នកជម្លៀសគ្មានថ្ងៃណាទំនេរ ឡើយ ប្រឹងដើម្បីប្តូរមកវិញនូវរបបអាហារមិនគ្រប់គ្រាន់តាមសេចក្តីត្រូវការ។ ការហូបចុក និងដើរហើរសុទ្ធ តែមានការពិនិត្យពិច័យនិងយាមកាមយ៉ាងត្រឹមត្រូវបំផុតពីប្រធានកង មិនដូចប្រជាជនមូលដ្ឋានឡើយ។ ប៉ុន្តែ ទោះជាយ៉ាងនេះការសម្លាប់នៅតែមានកើតឡើងមិនអាចខានបាន និងមិនរើសមុខ។ ប្រជាជន១៧មេសាទាំង អស់ត្រូវបានបណ្តើរយកមកសម្លាប់ទាំងខ្សែៗនៅក្នុងអណ្តូងដង្កោសាំង។ ហេតុការណ៍សម្លាប់មនុស្សនេះត្រូវ បានលោកពូសាំង សុខារៀបរាប់ថា គាត់បានឃើញ ស្ទើរលោះថ្ងៃនូវការបណ្តើរមនុស្សមកសម្លាប់ម្តងបួន ប្រាំនាក់នៅក្នុងអណ្តូងឪពុករបស់គាត់ នៅពេលដែលគាត់កំពុងបំពេញការងារជាមួយបងប្អូនឯទៀតនៅលើដី ចំការមួយដែលឃ្លាតតែប្រមាណជិត១០០ម៉ែត្រប៉ុណ្ណោះពីកន្លែងសម្លាប់។ ការបណ្តើរអ្នកទោសមកសម្លាប់ ច្រើនប្រព្រឹត្តទៅនៅម៉ោងប្រហែលជា៥ ឬ៦ព្រឹក។ អ្នកទោសទាំងនោះមិនត្រូវបានសម្លាប់ភ្លាមៗទេ គឺត្រូវ រង់ចាំការប្រមូលឲ្យបានច្រើនសិនទើបធ្វើការបោសសម្អាតម្តង។ នៅរៀងរាល់ការបោសសម្អាតម្តងៗ តែងតែ មានការចាក់ចម្រៀងបដិវត្តន៍តាមមេក្រូបន្លឺឡើងពេញរំពងព្រៃ ធ្វើឲ្យអារម្មណ៍ប្រជាជនដែលកំពុងធ្វើការងារ ជា ពិសេសលោកពូសាំង សុខានឹកគិតដល់ជីវិតរបស់ខ្លួនទៅថ្ងៃក្រោយ តើអាចថែរក្សាបានឬអត់?!។ ការសម្លាប់ ច្រើនប្រព្រឹត្តទៅនៅម៉ោងពារសៀល។ សម្លេងមេក្រូបានបញ្ចប់ពេលណា ការកម្ទេចក៏បានបញ្ចប់ពេលនោះ ដែរ។ កន្លែងដែលធ្លាប់តែមានសម្លេងអ៊ូអរ បានក្លាយជាព្រៃខ្មោចស្ងាត់ឈឹងគួរឲ្យព្រឺក្បាលនិងញាក់សាច់។ អាវុធមិនត្រូវយកមកធ្វើជាឧបករណ៍សម្លាប់ទេ។ ប្រជាជនដែលបានមកបញ្ចប់ជីវិតនៅក្នុងអណ្តូងនេះ ត្រូវបាននាំមកពីកន្លែងផ្សេងៗទៀតក្នុងឃុំព្រះធាតុ បូករួមទាំងប្រជជនថ្មីដែលមានទីលំនៅបណ្តោះអាសន្ននៅក្នុង វត្តព្រះធាតុផង។ ចំណែកប្រជាជនមូលដ្ឋានក៏មានការសម្លាប់ដូចគ្នាដែរ ប៉ុន្តែលុះត្រាតែអ្នកនោះមានកំហុស។ ការសម្លាប់អ្នកមូលដ្ឋាន គឺតម្រូវឲ្យជិករណ្តៅដោយខ្លួនឯង ទើបមានការវ៉ៃសម្លាប់ជាក្រោយ។ អ្នកមូលដ្ឋាន ដែលបានមកស្លាប់នៅទីតាំងចម្ការចេកជិតអណ្តូងតាសាំងនេះ សុទ្ធតែមិនដឹងខ្លួនថាខ្លួនបានសាងនូវកំហុសអ្វី ឡើយ។ លោកអ៊ំធុច ទុយ អាយុ៦៨ឆ្នាំ ដែលត្រូវជាឪពុកបង្កើតរបស់នារីពេទ្យខ្មែរក្រហមម្នាក់ដែលត្រូវ បានពួកខ្មែរក្រហមដូចគ្នាសម្លាប់ បានរៀបរាប់ពីការសម្លាប់នេះថា កូនស្រីរបស់គាត់គ្មានកំហុសអ្វីទេ សូម្បីតែ

និយាយស្តីអ្វីឲ្យប៉ះពាល់ដល់បដិវត្តបន្តិចក៏គ្មានដែរ ។ ខំតែធ្វើការក្នុងមន្ទីរពេទ្យគ្មានពេលទំនេរឡើយ ។ ចំណែក ក្មួយស្រីរបស់លោកពូស៊ាន សុខាម្នាក់អាយុ១៨ឆ្នាំបានត្រូវសម្លាប់ដោយមិនដឹងមូលហេតុអ្វីបន្តិចសោះ ។ គាត់ និយាយបន្តថា ក្មួយស្រីគាត់បានទទួលបញ្ជាឲ្យទៅរៀនសូត្របន្ថែមពីមុខជំនាញពេទ្យ ប៉ុន្តែជាការបោកបញ្ឆោត ទៅវិញសោះ ព្រោះត្រូវបង្ខំឲ្យជីករណ្តៅដោយខ្លួនឯងនៅក្នុងព្រៃចេកមួយក្នុងដីឡូតាស៊ាន ហើយបន្ទាប់ត្រូវ បានសម្លាប់ដោយដំបងរបស់ពួកខ្មែរក្រហម ។ តាមប្រសាសន៍របស់លោកពូស្រ៊ុយ ប៊ុនសៀ ថាមានសាច់ព្រះ ញាតិវង្សមួយព្រះអង្គព្រះ «ទ្រង់កន្តុល» បានមកស្លាប់នៅក្នុងបរិវេណវត្តព្រះធាតុនេះដោយជម្ងឺ ។ អ្នកទោស ដែលត្រូវបានយកមកដាក់នៅវត្តព្រះធាតុនេះ ភាគច្រើនបំផុតជាស្រីៗដែលជាប្រពន្ធទាហាន និងអ្នកជាប់និន្នា ការពីសង្គម ។ បុរសដែលជាប្តីត្រូវ បញ្ជូនទៅកាន់វត្តជំរិលដើម្បីធ្វើការងារ ។ លោកអ៊ំធុច ទុយបានប្រាប់ថា ក្រោយពីបានប្រមូលប្រជាជនមកដាក់នៅវត្តព្រះធាតុមកនៅចុងឆ្នាំ១៩៧៦ ពួកខ្មែរក្រហមចាប់ផ្តើមបំបែក ប្រុសៗដែលជាប្តីចេញពីប្រពន្ធ ។ ហើយនៅចុងឆ្នាំ១៩៧៨ វាសនាស្រីៗទាំងនោះត្រូវមកបញ្ចប់ជីវិតនៅ អណ្តូងតាស៊ានទាំងអស់ ។ លោកពូ ស្រ៊ុយ ប៊ុនសៀបាននិយាយថា អ្នកដែលបណ្តើរ និងសម្លាប់ប្រជាជនចោលនៅអណ្តូងតាស៊ាន គឺជាពួកនិរតី ។ ការសម្លាប់មនុស្សមិនត្រូវបានប្រព្រឹត្តិទៅអស់រយៈពេលយូរឡើយ ។ លោកពូ សៀ បន្ថែមថាការសម្លាប់មនុស្សប្រើរយៈពេលតែជាងកន្លះខែប៉ុណ្ណោះ ហើយមានចាក់ទឹកអាស៊ីត ពីលើសាកសពដើម្បីកុំឲ្យស្អុយ កុំឲ្យហើម ។ នៅចុងបញ្ចប់ទីតាំងសម្លាប់អណ្តូងតាស៊ានគ្មានបានបន្សល់ទុកនូវ ជនរងគ្រោះណាម្នាក់នៅមានជីវិតរស់នៅឡើយ ។ ចំពោះការប៉ាន់ស្មានចំនួនជនរងគ្រោះនៅពាសពេញដីឡូ របស់អតីតជន្មោស៊ាន លោកពូធុច ទុយ លោកអ៊ំស្រ៊ុយ ប៊ុនសៀ និងលោកពូស៊ាន សុខា សុទ្ធតែនិយាយ ថាមានចំនួនពី៧០០ទៅ៨០០នាក់ ។ ចំនួនជនរងគ្រោះទាំងនេះមានទាំងប្រជាជនចាស់ និងប្រជាជនថ្មីដែល ជម្លៀសមកពីទីក្រុងភ្នំពេញ ។

## ឃុំជំរិល វត្តជំរិល

ក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើដំណើរតាមផ្លូវអភិវឌ្ឍន៍លេខ៧៣(ទិសដៅពី ស្រុកអូររាំងឪទៅស្រុកស្នួល) ។ ទៅដល់សាលាឃុំជំរិលក្រុមយើងបានចុះធ្វើការទាក់ទងជាមួយអាជ្ញាធរ មូលដ្ឋាន រួចក៏ធ្វើដំណើរបន្តមកកាន់វត្តជំរិលដែលជាទីតាំងពិឃាតមនុស្សកាលពីសម័យខ្មែរក្រហម ។ នៅជុំវិញបរិវេណ វត្តជំរិល ខាងជើង ខាងត្បូង ខាងលិច និងក្នុងវត្តជំរិល មានទីតាំងសម្លាប់ចំនួន៥ និងមន្ទីរសន្តិសុខ១ ។ ទីតាំងទាំងនោះគឺៈ

២) ទីតាំងសន្តិសុខ និងកន្លែងសម្លាប់វត្តដំរិល លេខកូតភូមិសាស្រ្តៈ ០៣១១០៥

រយៈកំពស់ **(N) 11º 49' 15:29"** រយៈទទឹងៈ **(E) 105º 37' 40:88"**

មន្ទីរសន្តិសុខ

កុដ្តធំនៃវត្តដំរិលមួយដែលសង់ពីបេតុងប្រកក្បឿងស្ថិតនៅចំហៀងខាងជើងព្រះវិហារ ត្រូវបានជ្រើស រើសយកធ្វើជាមន្ទីរឃុំឃាំងបណ្តោះអាសន្នរបស់ពួកខ្មែរក្រហម ។ ជនរងគ្រោះភាគច្រើនមុននឹងសម្លាប់សុទ្ធ តែបានឆ្លងកាត់ការឃុំខ្លួននៅមន្ទីរឃុំឃាំងបណ្តោះអាសន្ននេះសិន ទើបសម្រេចកម្ទេចជាក្រោយ ។ លោកតា សួស ស៊ីម អាយុ៦៧ឆ្នាំ មានទីលំនៅនៅភូមិដំរិលទី១ ឃុំដំរិល ស្រុកអូរាំងឪ បាននិយាយប្រាប់ថា កាលពី សម័យប៉ុលពត គាត់ជាជាងដែកធ្វើកាំបិត ធ្វើពូថៅ ធ្វើចប ធ្វើខ្នៃវនៅក្នុងទីតាំងវត្តដំរិល ។ គាត់បានឃើញ និងដឹងច្បាស់ថា ពួកខ្មែរក្រហមបានយកកុដ្តធំនេះ ធ្វើជាទីតាំងសម្រាប់ស្តុបមនុស្សដែលប្រុងនឹងសម្លាប់ ចោល ។ ចំណែកលោកតាឃួន ស៊ីម បានបញ្ជាក់ថា ទីតាំងវត្តដំរិលនេះ ត្រូវពួកខ្មែរក្រហមយកធ្វើជាមូលដ្ឋាន ឃុំឃាំងអ្នកទោសផង និងកន្លែងហូបចុកប្រចាំឃុំទាំងមូលផង ។ លោកតាបន្តថា កន្លែងឃុំឃាំងអ្នកទោសមាន ពីរកន្លែងក្នុងវត្តដំរិលគឺមួយនៅក្នុងកុដ្តធំ និងមួយទៀតនៅក្នុង សាលាសំរាប់រៀនសីល-រក្សាសីល ។ ប្រភេទជនរងគ្រោះដែលយកមកដាក់ស្តុបនៅវត្តនេះ ហើយក្រោយមកត្រូវបានកម្ទេចចោលជាប្រភេទប្រជាជនទូទៅទាំងអ្នកជាប់និន្នាការពីសង្គមចាស់ និងអ្នករកស៊ីធម្មតា ។ តាមប្រសាសន៍របស់លោកតាថាគ្មានការធ្វើទារុណ កម្មដល់អ្នកទោសទេ ហើយការស្តុបមនុស្សទុកនេះគឺមិនប្រើរយៈពេលយូរឡើយ ។ អ្នកទោសទាំងអស់ត្រូវ បញ្ចេញយកទៅសម្លាប់នៅកន្លែងមួយចំនួនជុំវិញរបងវត្តដូចជានៅជាប់របងវត្តប៉ែកខាងត្បូង នៅទួលតាក្រៃ ដែលមានចម្ងាយប្រហែលជា១៥០ម៉ែត្រពីវត្តប៉ែកខាងត្បូង នៅទួលត្រពាំងឈូកដែលមានចម្ងាយប្រហែល ១០០ម៉ែត្រប៉ែកខាងជើងវត្តដំរិល និងនៅកន្លែងផ្សេងៗទៀត ។ មន្ទីរឃុំឃាំងបណ្តោះអាសន្ននេះបានបង្កើត ឡើងតាំងពីឆ្នាំ១៩៧៣មក ហើយការសម្លាប់ក៏ចាប់ផ្តើមនៅឆ្នាំនេះដែរ ។

## ទីតាំងសម្លាប់ជាប់របងវត្តដំរិល

មានទីតាំងសម្លាប់មួយទៀតនៅជាប់របងវត្តខាងក្រៅប៉ែកខាងលិចឆៀងខាងត្បូងវត្តដំរិល ។ ទីតាំង សម្លាប់នេះ ពួកខ្មែរក្រហមបានសម្លាប់តែប្រភេទជនរងគ្រោះជាមេសង្កាត់ និងអ្នកដែលពាក់ពន្ធ័

ជាមួយ សន្លាត់ៗ លោកតា ស៊ីម បានបញ្ជាក់ថា មេសន្លាត់ដែលត្រូវសម្លាប់គឺ ជាមេសន្លាត់របស់ខ្មែរក្រហមដូចគ្នា ប៉ុន្តែមានកំហុសរឿងអីនោះ លោកតាមិនបានដឹងឡើយ ។ តាមតារាងស្ថិតិអំពីរណ្ដៅសាកសព និងចំនួនជនរងគ្រោះដែលបានស្វាប់របស់ការិយាល័យធម្មការស្រុក បានឲ្យដឹងថានៅជាប់របងវត្តជីរិលនេះ មានសម្លាប់ជនរងគ្រោះអស់១៥នាក់ ហើយកប់តែមួយរណ្ដៅទេ ។

៣) ទីតាំងសម្លាប់ទួលតាក្រៃ លេខកូតភូមិសាស្ត្រៈ ០៣១១០៦

រយៈកំពស់ (N) 11º 49' 09:68" រយៈទទឹងៈ (E) 105º 37' 36:99

ទួលតាក្រៃ

ជាទួលមួយស្ថិតនៅចំកណ្ដាលវាលស្រែដែលមានចម្ងាយប្រហែលពី១០០-១៥០ម៉ែត្រពីរបងវត្ត ជីរិលប៉ែកខាងត្បូងដែលមានរណ្ដៅចំនួន៤ ដែលមានជម្រៅមួយម៉ែត្រកន្លះ បណ្ដោយវែងនិងទទឹងប្រហែល ជាងកន្លះម៉ែត្រ ។ តាមសាក្សីមិនស្គាល់ឈ្មោះពីរនាក់ដែលបានជូនក្រុមយើងទៅថតកន្លែងទួលតាក្រៃនោះបាន និយាយថារណ្ដៅនៅលើទួលតាក្រៃនេះ ជាបៃយោរបស់ទាហានកាលពីមុនប៉ុន្តែលុះដល់តំបន់នេះ ធ្លាក់ក្នុងការ កាន់កាប់របស់ខ្មែរក្រហម បៃយោនេះបានក្លាយជាកន្លែងដាក់សាកសព មនុស្សទៅវិញ ។ តាមសម្ដីរបស់លោក តា ស៊ីម និយាយថាការសម្លាប់មនុស្សនៅលើទីតាំងនេះ គឺមានតាំងពីឆ្នាំ១៩៧៣មក ។ ហើយប្រភេទជនរង គ្រោះ គឺភាគច្រើនជាទាហានលន់ណុលដែលបាក់ទ័ពហើយត្រូវចាប់បាន ។ លោកតាបានបន្ថែមថាចំពោះទាហាន ណាម្នាក់ដែលរបួសហើយរត់មកលាក់ពួននៅតាមផ្ទះរបស់បងប្អូន ឬ សាច់ញាតិ ត្រូវតាមមកចាប់យកទៅ សម្លាប់ចោលភ្លាមៗដោយមិនចាំបាច់ឃុំឃាំងឡើយ ។ ការសម្លាប់ច្រើនប្រើដំបងជាឧបករណ៍សម្លាប់ ។ លោក តា យួន ស៊ីម អាយុ៧៤ឆ្នាំ បានរៀបរាប់ពីការសម្លាប់មនុស្សថា“ខ្ញុំគ្រាន់តែបានលបមើលឃើញពីចម្ងាយ នូវ ការសម្លាប់មនុស្សប៉ុណ្ណោះ ។ គេសម្លាប់ភាគច្រើននៅម៉ោង៧-៨យប់ ពេលដែលស្ងាត់មនុស្សឆ្លងកាត់” ។ មានក្រុមព្រះរាជវង្សានុវង្សមួយព្រះអង្គក៏បានមកបញ្ចប់ជីវិតនៅក្នុងបរិវេណវត្តនេះដែរគឺឈ្មោះ រិទ្ធិវង្ស ។ តាមប្រសាសន៍របស់លោកតា យួន ស៊ីមថា រិទ្ធិវង្សនេះ ជាសាច់ញាតិផ្ទាល់ជាមួយទ្រង់កណ្ដុលដែលបាន ស្លាប់នៅវត្តព្រះធាតុដោយជម្ងឺកាលពីឆ្នាំ១៩៧៥ ។ លោកតាបន្តថារិទ្ធិវង្សបានស្រែកព្រហូតដល់ភូមិប្រជាជន រស់នៅ ពេលដែលពួកខ្មែរក្រហមធ្វើទារុណកម្មមុនពេលសម្លាប់ ។

៤) ទីតាំងសម្លាប់ត្រពាំងឈូកនិងត្រពាំងក្តាម លេខកូតូភមិសាស្រ្តៈ ០៣១១០៧

រយៈកំពស់ (N) 11º 49' 20:80" រយៈទទឹងៈ (E) 105º 37' 42:51"

ទីតាំងសម្លាប់ត្រពាំងឈូកស្ថិតនៅខាងខាងកើតឆៀងខាងជើងវត្តដំរិលប្រហែល១០០ម៉ែត្រ ។ បច្ចុប្បន្នទីតាំងនេះហាក់ដូចជាស្រះទឹកមួយដែលពុំមានទឹកទាល់តែសោះ ។ មានរណ្តៅកប់សាកសព ចំនួន ៥កាល ពីជំនាន់ខ្មែរក្រហម ។ រណ្តៅទាំងនេះសុទ្ធតែបានកប់មនុស្សពេញៗមុននឹងលុបដីទៅវិញ ។

ទីតាំងសម្លាប់ត្រពាំងក្តាមមានពីររណ្តៅដែរ ។ ទីតាំងនេះស្ថិតនៅខាងកើតឆៀងខាងជើងទីតាំងត្រពាំង ឈូកប្រហែលជាង១០០ម៉ែត្រ ។ លោកតា ស៊ឹមបាននិយាយថា រណ្តៅទាំងពីរនៅត្រពាំងក្តាម គឺមានទំហំ ធំជាងគេបង្អស់ក្នុងមួយបរិវេណវត្តដំរិលនេះ ។ លោកតាបានបន្តថា ការសម្លាប់មនុស្សគឺមាន លាយចំរុះគ្នា មានទាំងក្មេងដែលមិនទាន់ចេះដើររហូតដល់ចាស់ៗ ។ ការសម្លាប់ច្រើនប្រើព្រនង់ជាឧបករណ៍ ។ ចំពោះជនរង គ្រោះដែលបានមកស្លាប់នៅទីនេះគឺមាន ប្រជាជនមូលដ្ឋានខ្លះ និងប្រជាជនថ្មីភាគច្រើន ។ ក្នុងពេលដែលលោក តាធ្វើការនៅក្នុងវត្តដំរិល លោកតាបានឃើញពួកទាហានខ្មែរក្រហមបំផ្លាញវត្ត ជាពិសេសកុដ្ឋជាច្រើនត្រូវបាន រុះរើទាំងអស់ ទុកតែកុដ្ឋធំមួយសម្រាប់ដាក់អ្នកទោសប៉ុណ្ណោះ ។ ចំពោះការគោរពបូជាព្រះពុទ្ធសាសនាវិញ លោកតា និយាយថា គ្មាននរណាម្នាក់ហ៊ានចេញមុខទៅថ្វាយបង្គំព្រះនៅក្នុងព្រះវិហារឡើយ បានត្រឹមតែលួចថ្វាយបង្គំនៅតាមកន្លែងដែលស្នាក់នៅប៉ុណ្ណោះ ។ ព្រះសង្ឃទាំងអស់នៅក្នុងវត្តត្រូវបានផ្សឹកក្រោមបញ្ជាដាច់ខាតមួយ ។ លោកពូសាំង សៀន អាយុ៥២ឆ្នាំ មានទីលំនៅភូមិចន្ទ័អណ្តែត ឃុំទួលទួលសុភី ស្រុក អូរាំងឪ បានរៀបរាប់ប្រាប់ថា ចំពោះការផ្សឹកព្រះសង្ឃ គឺសុទ្ធតែមានការគំរាមជាពាក្យសម្តីព្រមទាំងមានភ្ជង់កាំភ្លើង ទៀតផងចំពោះការមិនព្រមសឹក ។ លោកពូបន្ថែមថាគាត់បានស្តាប់ឮផ្ទាល់នឹងត្រចៀកនូវពាក្យគំរាមយ៉ាង អសីលធម៌ជាច្រើនរបស់ពួកខ្មែរក្រហមមកលើព្រះសង្ឃ ។ ព្រះពុទ្ធបដិមាករមួយចំនួនត្រូវបានកប់ក្នុងដីចោល ហើយក្រោយជ័យជំនះក៏នៅតែរកមិនឃើញ ។ ទីវត្តអារ៉ាមត្រូវបិទទ្វារ មានតែមនុស្សធ្វើការតែប៉ុន្មាននាក់ ប៉ុណ្ណោះ ហើយក្រៅពីនេះ មានតែពួកកងឈ្លប កងសន្តិសុខក្នុងសម្លៀកបំពាក់ខ្មៅដើរចុះឡើងៗពេញទីធ្លាវត្ត ។ តាមរបាយការណ៍ពីការិយាល័យធម្មការស្រុកអូរាំងឪបានឲ្យដឹងថា ទីតាំងត្រពាំងឈូកមានសាកសពប្រមាណ ៥០នាក់ និងត្រពាំងក្តាមមាន ៣៥នាក់ ។ ចំនួនសាកសពសរុបគឺ ប្រមាណ៨៥នាក់ ។

**ឃុំចក**

៥) ទីតាំងសម្លាប់ទួលកន្លួត លេខកូតភូមិសាស្ត្រៈ ០៣១១០៨

រយៈកំពស់ **(N) 11º 47' 00:22"** រយៈទទឹងៈ **(E) 105º 35' 42:29"**

ក្រុមស្រាវជ្រាវយើងបានធ្វើដំណើរបន្តពីវត្តដំរិល ឃុំដំរិលតាទិសដៅពីជើងទៅត្បូងប្រមាណ ៥គីឡូ ម៉ែត្រតាមបណ្តោយផ្លូវជាតិលេខ៧៣(ផ្លូវអភិវឌ្ឍន៍ជនបទ) មកដល់ខ្លោងទ្វារវត្តជ្រួល ឃុំចក បត់មកទិសខាង លិចឆ្ពោះមកកាន់វត្តជ្រួល ។ ទិសដៅរបស់យើងមិនចូលវត្តជ្រួលទេ គឺធ្វើដំណើរ សរសៀរតាមរបងវត្តឆ្ពោះ មកកាន់ទីតាំសម្លាប់មួយឈ្មោះទួលកន្លួត ។ ទីតាំងសម្លាប់វត្តជ្រួលស្ថិត នៅខាងលិចវត្តជ្រួលប្រហែលជាងមួយ គីឡូម៉ែត្រ និងស្ថិតនៅក្នុងភូមិជ្រួល ឃុំចក ស្រុកអូររាំងឪ ។ ទីតាំងនេះតាមរបាយការណ៍ក្នុងតារាងស្ថិតិពីសា លាស្រុក ក៏ដូចជាកាសាកសួរពត៌មានពីអ្នកដឹងព្ធដែរថា មានចំនួនតែ២រណ្តៅទេ ។ រណ្តៅទាំង២នេះស្ថិតនៅ ចម្ងាយពីគ្នាប្រហែល៣០ម៉ែត្រ ។ លោក អ៊ុន អៀន បាននិយាយប្រាប់នៅជិតអតីតរណ្តៅធំមួយក្នុងទួល កន្លួតថា គាត់បានឃើញការសម្លាប់មនុស្ស ស្រីម្នាក់បន្ថែមពីលើមនុស្សដែលបានស្លាប់ស្រាប់រាប់សិបនាក់ទៀត ការសម្លាប់នោះ គាត់និយាយថា អំពើដែលពួកខ្មែរក្រហមបានធ្វើមកលើជនរងគ្រោះគឺសាហាវណាស់ ។ ស្ត្រី ម្នាក់នោះត្រូវបានសម្លាប់ ដោយពួកខ្មែរក្រហមយកមែកឈើ(មែកសង្កែ) ទៅបុកលើទ្វារមាសស្ត្រីនោះរហូតដល់ ស្លាប់ ។ ក្រោយ ការសម្លាប់គាត់បានទៅពិនិត្យឃើញដាក់ស្ដែងដូចគាត់បានលបមើលពីចម្ងាយមែននូវមែកឈើ ដែល ដោតជាប់ឆ្អឹងចំកណ្តាលថ្កុកឈាមដែលចេញពីរាងកាយស្ត្រីនោះ ។ លោកអ៊ឹ ឆែ ហៃ អាយុ៦៥ឆ្នាំ ជា ប្រជាជនរស់នៅភូមិព្រីង ឃុំចកបាននិយាយប្រាប់ថា ស្ត្រីដែលស្លាប់នោះត្រូវជាម្តាយមីងរបស់ គាត់ឈ្មោះ ឡេង ។ គាត់បន្តថា ក្រោយការសម្លាប់គាត់បានមកមើលភ្លាម ។ មុនដំបូងគាត់បានឃើញ កន្ត្រកស្លាមួយដែល នៅលើស្មៅក្បែរសាកសពដែលមើលមិនចង់ស្គាល់ ។ លោកអ៊ឹ ហៃបានសន្និដ្ឋាន ភ្លាមថា ជាកន្ត្រកស្លារបស់ ម្តាយមីងគាត់ឈ្មោះ ឡេងហើយ ព្រោះគាត់ធ្លាប់ឃើញយាយ ឡេង ប្រើរាល់ថ្ងៃ ។ លោកពូបានបន្តថា ការ សម្លាប់មនុស្ស នៅទួលកន្លួតនេះមានសម្លាប់តែប្រពន្ធ កូន សាច់ញាតិ ឬមនុស្សដែលពាក់ពន្ធ័ជាមួយនឹងពួក កម្មាភិបាលដែល ក្បត់នឹងអង្គការបដិវត្តន៍ បន្ទាប់ ពីមានការកុហកបំបែកកម្មាភិបាលរូបនោះចេញពីប្រពន្ធកូន ថាឲ្យទៅរៀនសូត្រ នៅកន្លែងផ្សេង ។ ក្រោយបំបែកមិនបានប៉ុន្មានផង ប្រពន្ធ កូននៅឯផ្ទះត្រូវដឹកយកមក សម្លាប់ទាំងអស់នៅ ទួលកន្លួត នេះ ។ ការសម្លាប់ប្រព្រឹត្តិនៅចុងឆ្នាំ១៩៧៨ ។ ពេលយប់ ជាពេលវេលាដ៏ល្អ ក្នុងការសម្លាប់មនុស្ស នៅលើទួលកន្លួតនេះ ។ លោកអ៊ឹ ឆែ ហៃ បានប្រាប់ថា គាត់បានឃើញផ្ទាល់ភ្នែកនូវ សាកសពយ៉ាង រដូករណែកគរលើគ្នា ហើមរលួយស្មើរចូលទៅជិតមិនបាន ។ លោកអ៊ឹបានឱ្យបប្រាប់ថា មូល ហេតុ

ដែលគាត់អាចចូលមកលបមើលបាន គឺមកពីពួកខ្មែរក្រហមទៅប្រជុំនៅអូររាំងឪ ម្យ៉ាងទៀតគាត់ភ្លូរនៅជិត ហ្នុងផង។ លោកអ៊ឹំបានសំដែងទឹកចិត្តខឹងប្រឡោតយ៉ាងខ្លាំងចំពោះពួកខ្មែរក្រហមដែលបានសម្លាប់បងប្អូនគាត់ ប៉ុន្តែមិនហ៊ានធ្វើអ្វី បានត្រឹមតែលាក់ទុកក្នុងចិត្ត។ ចំពោះជនរងគ្រោះដែលបានស្លាប់នៅលើទួលកន្ទួតនេះ តាមរបាយការណ៍ពីការិយាល័យធម្មការ និងសាសនាស្រុកអូររាំងឪបានឲ្យដឹងថា មានចំនួន៤៣នាក់។

៦) ទីតាំងសម្លាប់ចំការគាសន លេខកូតភូមិសាស្រ្តៈ ០៣១១០៩

រយៈកំពស់ **(N) 11º 46' 50:11"** រយៈទទឹងៈ **(E) 105º 35' 40:45"**

បើយើងធ្វើដំណើរចេញពីទីតាំងសម្លាប់ទួលកន្ទួតឆ្ពោះមកទិសខាងត្បូងតាមបណ្តោយផ្លូវលំក្រោយរបងវត្តជ្រួលប្រមាណជាងមួយគីឡូម៉ែត្រ យើងនឹងបានមកដល់ទីតាំងសម្លាប់មួយទៀតឈ្មោះថាចំការគាសន។ បច្ចុប្បន្នទីតាំងនេះស្ថិតនៅវាលស្រែដាច់ឆ្ងាយពីភូមិប្រជាជនរស់នៅ។ លោកអ៊ឹំ សូជន់ អាយុ៦៨ឆ្នាំ ជា មន្ត្រីចូលនិវត្តន៍ បានឲ្យដឹងថា នៅចំការគាសននេះមានរណ្តៅមួយវែងដែលលាតសន្ធឹងពីកើតទៅលិចប្រវែង ប្រហែលជាង១០ម៉ែត្រ ដែលពួកខ្មែរក្រហមយកធ្វើជាកន្លែងកប់ខ្មោចដែលវាសម្លាប់។ លោកអ៊ឹំបញ្ជាក់ថា តាមពិតរណ្តៅនេះ ជាលាណដ្ឋានរបស់កងទ័ព ស-២០៤ ក្នុងការលាក់បំពួនកុំឲ្យយន្តហោះទំលាក់គ្រាប់បែក លើប៉ុណ្ណោះ។ លោកអ៊ឹំបានប្រាប់បន្តថា មាននារីម្នាក់ឈ្មោះ សា បានត្រូវសម្លាប់នៅក្នុងរណ្តៅនេះ ដោយ មូលហេតុខ្លួនជានិរសារដែលបានក្បត់ជាមួយអង្គការ។ ក្រោយពីនារី សារ មកមានសម្លាប់ជាហូរហែរគ្មាន ដាច់ឡើយ។ តាមប្រសាសន៍របស់លោកអ៊ឹំថា អ្នកដែលបានមកស្លាប់នៅទីនេះ សុទ្ធតែមានការចោទប្រកាន់ថា ជាសេអ៊ីអារបស់ខ្មាំង។ ពួកជនរងគ្រោះដែលស្លាប់ទាំងនោះ មុននឹងយកមកសម្លាប់នៅក្នុងលាណដ្ឋានកងទ័ព នៅចំការគាសននេះ គឺបានយកមកឃុំឃាំងបណ្តោះអាសន្ននៅក្នុងរោងម៉ាស៊ីនកិនស្រូវមួយកន្លែងដែលស្ថិតមិនឆ្ងាយប៉ុន្មានពីទីតាំងនេះ។ មានម្នាក់ទៀតឈ្មោះ សៀត បានមកស្លាប់នៅក្នុងរណ្តៅនៃចំការគាសនដែរពីបទ ជាសេអ៊ីអា។ លោកអ៊ឹំប្រាប់ថា សៀត នេះជាអ្នកដែលមានគុណសម្បត្តិច្រើនក្នុងដួរបដិវត្តន៍របស់ពួក គេ(ខ្មែរ ក្រហម) ប៉ុន្តែទីបញ្ចប់ ត្រូវមកបញ្ចប់ជីវិតនៅលើចំការគាសនដោយជៀសមិនផុត។ មានរណ្តៅចំនួន៦ និង សាកសពចំនួន១៨នាក់។

## ឃុំធ្នួលសុភី

៧) ទីតាំងសម្លាប់ទួលមនោរម្យ លេខកូតភូមិសាស្រ្តៈ ០៣១១១០

រយៈកំពស់ **(N) 11º 48' 56:83"** រយៈទទឹងៈ **(E) 105º 33' 32:91"**

ទីតាំងសម្លាប់ទួលមនោរម្យ ជាទីតាំងមួយដែលបច្ចុប្បន្នមានទួលខ្ពស់ ហើយប្រជាជនកសិករនៅភូមិ ចន្ទ័អណ្តែត ឃុំទួលសុភី ប្រមាណបីបួនគ្រួសារនាំគ្នាដាំដំណាំនៅលើទួលនោះ ដូចជាដើមខ្នុរ ដើមដូង និងបន្លែ ហូបផ្លែមួយចំនួន។ ទីតាំងនេះស្ថិតនៅក្នុងទឹកដីភូមិចន្ទ័អណ្តែត ឃុំទួលសុភី ស្រុកអូរាំងឪ ។ កាលពីជំនាន់ប៉ុលពត ទួលមនោរម្យនេះបានក្លាយទៅជាទួលសម្លាប់មនុស្សយ៉ាងសាហាវមួយប្រចាំឃុំទួលសុភី។ នៅលើទួលនេះមាន រណ្តៅ ធំៗចំនួនពីរ ហើយរហូតមកដល់ឥឡូវស្លាកស្នាមទាំងឡាយមិនបានបន្សល់ទុកឡើយ ។ ពេលដែលក្រុម ស្រាវជ្រាវយើងធ្វើដំណើរទៅដល់ យើងសង្កេតឃើញប្រជាកសិករយើងនាំគ្នាធ្វើស្មៅសម្អាតចំការសណ្តែត ប្រមាណ៤-៥នាក់ ។ រណ្តៅដែលធំជាងគេ ត្រូវបានម្ចាស់ចំការដាំដើមខ្នុរមួយដើមទុកជាចំណាំ ។ នៅពេល ដែលយើង សួរទៅគាត់ គាត់និយាយថា គាត់ដាំសម្រាប់ចំណាំ និងងាយស្រួលប្រាប់ទៅក្មេងៗក្រោយៗថា កន្លែងដែលដាំដើមខ្នុរនេះ ជាកន្លែងសម្លាប់មនុស្សរអស់រាប់ពាន់នាក់កាលពីជំនាន់ខ្មែរក្រហម ។ ការសម្លាប់ មនុស្សនៅលើទួលមនោរម្យនេះ ប្រព្រឹត្តិទៅនៅចុងឆ្នាំ១៩៧៨ ពេលដែលពួកខ្មែរក្រហមខាងនិរតីចូលមកត្រួតត្រា ។ លោកអ៊ឹំ អ៊ិន អៀន បានបញ្ជាក់ប្រាប់ថា ក្រោយពេលដែលពួកខ្មែរក្រហមសម្លាប់មនុស្សរួច ពួកវាបានកប់ដីពីលើរណ្តៅ ហើយបានយកដើមចេក និងដើមអំពៅមកដាំពីលើរណ្តៅនេះទៀត ។ លោកអ៊ឹំ និយាយបន្តថា មូលហេតុពួកវាធ្វើយ៉ាងនេះ គឺដើម្បីបំភាន់ភ្នែកអ្នកស្រុកមិនឲ្យដឹងពីការសម្លាប់របស់ពួកវា ។ លោកអ៊ឹំព្រមទាំងមិត្តភក្រ័ម្នាក់ទៀតឈ្មោះ តាក់ បាននាំគ្នារត់ចេញពីកន្លែងដែលពួកខ្មែរក្រហមដាំដើមចេកពី លើផ្នូរខ្មោចរាប់ពាន់នោះទាំងសភាពភ័យតក់ស្លុត ។ ប្រជាជនភាគច្រើនទាំងមូលដ្ឋានចាស់និងថ្មី សុទ្ធតែត្រូវបាន ជម្លៀសបន្តទៅកាន់ខេត្តកំពង់ធំនៅឆ្នាំ១៩៧៨ និងមួយចំនួនទៀតត្រូវចេញបញ្ជាកម្ទេចចោលទាំងគ្មានកំហុស ។ មានប្រជាជនជាងមួយពាន់នាក់ បានស្លាប់និងកប់នៅលើដីទួលមនោរម្យនេះ ។ ល្បិចបោកបញ្ឆោតមនុស្ស យកមកសម្លាប់នៅលើទួលមនោរម្យ ត្រូវបានលោកតូ សាំង សៀន អាយុ៥២ឆ្នាំ ជាប្រជាជនរស់នៅភូមិ ចន្ទ័អណ្តែត ឃុំទួលសុភី អធិប្បាយថា ពួកខ្មែរក្រហម បានប្រមូលប្រជាជន ប្រមូលទាហានពីកន្លែងផ្សេងៗ ក្នុងឃុំទួលសុភីទាំងអស់មកប្រជុំ ដើម្បីរំសាយឲ្យទៅកាន់អង្គភាពវិញ ។ ចំពោះប្រជាជន១៧មេសាវិញ គឺពួក ខ្មែរក្រហមប្រជុំប្រកាសថា ឲ្យវិលត្រឡប់ទៅកាន់ស្រុកកំណើត ឬទៅកាន់ភ្នំពេញវិញ ។ ការពិត នេះជាពាក្យ កុហករបស់ខ្មែរក្រហមប៉ុណ្ណោះ ។ មនុស្សទាំងឡាយក្នុង ឃុំទួលសុភី ត្រូវបានសម្លាប់ទាំងអស់ ។ លោកតូ

សាំង សៀន ប្រាប់បន្តថា «បើនិយាយពីឃុំទួលទួលសុភីគឺ១៩ភូមិ ហើយមានយកមកពីឃុំចកខ្លះទៀត គឺ ប្រមូលមកទាំងអស់ ។ នេះបានន័យថាវាច្រើនដែរ រណ្តៅ២ហ្នឹងគឺ ពេញៗអញ្ចឹងម៉ង» ។ លោកពូបានឃើញ ការបណ្តើរមនុស្សមកសម្លាប់នៅលើទួលមនោរម្យនេះផ្ទាល់នឹងភ្នែក នៅតាមចន្លោះដើមចេក និងដើមអំពៅ ពេលដែលគាត់កំពុងឃ្វាលគោឲ្យស៊ីស្មៅ ។ លោកពូបានប្រាប់ទៀតថា អ្នកទោសទាំងនោះភាគច្រើនជាអ្នកដែល ជាប់និន្នាការពីសង្គមចាស់ និងកម្មាភិបាលខ្មែរក្រហមដូចគ្នាដែលត្រូវបានចាត់ទុកថាជាខ្មាំងក្បត់នឹងអង្គការ ។ ការ សម្លាប់នៅលើទួលនេះ ប្រព្រឹត្តទៅនៅចុងឆ្នាំ១៩៧៨ ហើយប្រើរយៈពេលបីថ្ងៃប៉ុណ្ណោះក្នុងការសម្លាប់ ។ គ្មាន ការសួរចម្លើយឡើយមុនពេលសម្លាប់ ។ ភាគច្រើននៃនារីភេទ ត្រូវបានរំលោភជាមុន ទើបសម្លាប់ជាក្រោយ ។ ពួកឃាតករ គឺជាពួកនិរតីដែលមានសម្ពីរជើនៗ និងពួកខាងភូមិភាគកណ្តាល ។ ការសម្លាប់ប្រព្រឹត្តទៅជាមួយ នឹងការចាក់មេក្រូបន្លឺឡើងរំពងពេញព្រៃ ។ លោកអ៊ំអ៊ិន អៀន និយាយថា«ការចាក់មេក្រូច្រើនបន្លឺឡើងនៅ រសៀលម៉ោង៤» ។ លោកតាឡូញ ឡាញ់និយាយថា គាត់បានឃើញពួកខ្មែរក្រហមកំពុងសម្លាប់មនុស្សនៅលើទួលមនោរម្យពេលដែលគាត់តាមរកគោរបស់គាត់ដែលបាត់ ។ លោកតាបានបន្តថា គាត់បានឃើញពួក ខ្មែរក្រហមមានគ្នាប្រមាណពី៥០ទៅ៦០នាក់កំពុងស្នាក់នៅក្នុងមន្ទីររបស់វាមួយនៅក្បែរទួលមនោរម្យនេះ ។ បរិវេណជុំវិញ កន្លែងសម្លាប់ត្រូវបានហាមឃាត់ ក្មេងឃ្វាលគោទាំងឡាយត្រូវបានបណ្តេញចេញទៅឆ្ងាយ ។ ក្រោយបែកឆ្នាំ១៩៧៩ លោកពូបានមកមើលរណ្តៅដែលសម្លាប់មនុស្សកាលពីចុងឆ្នាំ១៩៧៨ គាត់បានឃើញ រណ្តៅទាំងពីរ នេះមានស្រុតចុះឃើញស្នាមមាត់រណ្តៅយ៉ាងធំ ។ ហើយក្រោយមករណ្តៅទាំងពីរនេះត្រូវបាន គាស់យកឆ្អឹង ទាំងឡាយដាក់នៅលើមាត់រណ្តៅចំនួនពីរគំនរ ។ លោកពូបានប៉ាន់ស្មានថាមានចំនួនសាកសពរាប់ ពាន់នាក់ក្នុង រណ្តៅទាំងពីរនេះ ។ រណ្តៅទាំងពីរនេះមានចម្ងាយប្រហែល១០ម៉ែត្រពីគ្នា ។ រណ្តៅមួយៗមាន ទំហំប្រហែលជា ១០ម៉ែត្របួនជ្រុង និងជម្រៅពី៥-៦ម៉ែត្រ ។ លោកតា ទន អ៊ុម អាយុ៦១ឆ្នាំ រស់នៅ ភូមិដំណាក់កែវ ឃុំទួលសុភី បានពន្យល់ថា គាត់ជាម្ចាស់ចំការដែលមានរណ្តៅពីរនេះ ។ ក្រោយបែកឆ្នាំ ១៩៧៩ លោកតាបានមកឃើញរណ្តៅនៅក្រហត ហើយនៅមានឆ្អឹងជាប់សាច់ ហើយលលាដ៍ក្បាលមិនទាន់ ជ្រុះអស់សក់ដែរទេ ។ បន្ទាប់មកឪពុករបស់លោកអ៊ំបានប្រមូលឆ្អឹងដែលគេគាស់រួចដាក់ចូលក្នុងរណ្តៅវិញ ហើយលុបដីពីលើ ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ពេលដែលលោកអ៊ំភ្ជួររាស់ធ្វើចំការរាល់រដូវកាលពីមុន គាត់តែងតែជួបប្រទះឃើញឆ្អឹង លលាដ៍ក្បាលតាពីស តាពាសពេញដី ហើយគាត់ក៏រើសបោះចូលក្នុងរណ្តៅ ។ បន្ទាប់មក ដោយឃើញថាមានបានជួបទៀត គាត់ក៏លុបដីពីលើមួយសារ

ទៀត ហើយបានដាំដើមខ្នុរមួយ ដើមពីលើដីដែលលុបនោះទៅ។ ចំពោះការស្លាប់វិញ តាមរបាយការណ៍ ពីសាលាស្រុកថា មានចំនួនរហូតដល់ ទៅ១៨០៦នាក់។

សន្និដ្ឋាន

ទួលមនោរម្យ មានជនរងគ្រោះស្លាប់រាប់ពាន់នាក់តែក្នុងរយៈពេលបីថ្ងៃប៉ុណ្ណោះ នៅចុងឆ្នាំ១៩៧៨។ រណ្តៅមានចំនួន២ មួយធំដែលមានទំហំប្រមាណ១០ម៉ែត្របួនជ្រុង ជម្រៅពី៥-៦ម៉ែត្រ និងមួយទៀតតូច ដែលមានទំហំទទឹងប្រហែល៣ម៉ែត្រ បណ្តោយ៤ម៉ែត្រ និងជម្រៅពី៣-៤ម៉ែត្រដែរ។ ក្រោយការសម្លាប់ ពួកខ្មែរក្រហមបានលុបដីពីលើ ហើយមានដាំដើមចេកពីលើទៀត។ តាមសម្តីរបស់សាក្សីថា ដើម្បីបំភាន់ភ្នែក ប្រជាជន។ បច្ចុប្បន្នរណ្តៅដែលធំជាងគេនៅលើទួលមនោរម្យត្រូវបានម្ចាស់ចំការឈ្មោះ អ៊ឹម ដាំដើមខ្នុរ មួយដើម ដើម្បីចំណាំថាជាទីតាំងសម្លាប់មនុស្សកាលពីជំនាន់ប៉ុលពត។ គ្មានស្លាកស្នាមអ្វីបន្តិចនៅសេសសល់ ក្រៅពីកូនខ្នុរដែលទើបនឹងដាំនេះឡើយ។ វ៉ាន មនុស្សជាច្រើននាក់បានដឹងពីការសម្លាប់មនុស្សនៅលើទួល មនោរម្យនេះ។ នៅលើទួល ពិសេសនៅលើរណ្តៅទាំងពីរត្រូវបានម្ចាស់ចំការភ្ជួររាស់ រាន្តដីធ្វើចំការ។

៨) ទីតាំងគុកសន្តិសុខនិងកន្លែងសម្លាប់ភ្នំដី លេខកូតភូមិសាស្រ្តៈ ០៣១១១១
រយៈកំពស់ **(N) 11º 48' 27:81"** រយៈទទឹងៈ **(E) 105º 33' 08:18"**

ភ្នំដី ជាទីតាំងមួយស្ថិតនៅក្នុងភូមិភ្នំដី ឃុំទួលសុភី។ បច្ចុប្បន្នភ្នំនេះ នៅតែជាភ្នំមួយដែលឈរជន្រ្ទឹងយ៉ាងសង្ហារបង្អួតគេឯងគ្រប់គ្នាថាខ្លួននៅតែមានគេកោតខ្លាច។ កាលពីជំនាន់ប៉ុលពតភ្នំនេះបានក្លាយជា មន្ទីរសន្តិសុខរបស់ភូមិភាគបូព៌ាដែលគ្រប់គ្រងដោយឈ្មោះតែម ជាមនុស្សបន្ទាប់ពីសោភឹម។ គុកនេះត្រូវបាន សាងសង់ឡើងពីខឿនក្រោមជាបេតុង និងមានជញ្ជាំងក្តារ ប្រក់ក្បឿង។ ក្រោយបែកឆ្នាំ១៩៧៩ ប្រជជនដែលនៅសល់ពីស្លាប់បាននាំគ្នាទៅគាស់យកក្តារជញ្ជាំងមកធ្វើផ្ទះនៅ ឯខឿនក្រោមជាបេតុងនោះ គឺស្ថិតនៅ ទាល់តែរាល់ថ្ងៃ។ ក្រុមស្រាវជ្រាវយើងបានធ្វើដំណើរទៅកាន់ទីតាំងនោះ ដែលមានចម្ងាយប្រមាណ៧០០ ម៉ែត្រពីទីតាំងសម្លាប់ទួលមនោរម្យ។ ថ្វីត្បិតតែអាកាសធាតុនៅលើភ្នំដីនេះ ល្អបរិសុទ្ធ និងទេសភាពដ៏ត្រកាល គួរឲ្យចង់គយគន់ពិតមែន ប៉ុន្តែបើគិតត្រឡប់ក្រោយមកវិញពីការឃុំឃាំងមនុស្ស ការធ្វើទារុណកម្មមនុស្ស និងការសម្លាប់មនុស្សរបស់ក្រុមទាហានខ្មែរ

ក្រហមរបស់ភូមិភាគបូព៌ា កាលពីអំឡុងនៃការកាន់កាប់របស់ពួកគេ ពិតជាធ្វើឲ្យយើងនឿយណាយ និងមិននឹកចង់គយគន់ទេសភាពដ៏ត្រកាលទាំងនេះឡើយ ។ ប៉ុន្តែបើយើងក្រឡេក មើលទៅទិសខាងកើត ភ្នំដីនេះឲ្យច្បាស់ថែមទៀតនោះ យើងប្រាកដជាបានឃើញយ៉ាងច្បាស់នូវស្លាកស្នាម រណ្តៅក្រហេង ក្រហូងដែលបានបន្សល់ទុកពិតៗ ក្រោយការសម្លាប់មនុស្សកាលពីជំនាន់ខ្មែរក្រហម ។

រឿងរ៉ាវដែលបានកើតឡើងនៅលើភ្នំដីមិនត្រូវបានបំភ្លេចពីអារម្មណ៍របស់មនុស្សវ័យចំណាស់ៗ ក្នុង ឃុំថ្មដា និងឃុំទួលសុភីឡើយ ។ គ្រាន់តែរំលឹកពីការសម្លាប់មនុស្សកាលពីជំនាន់ខ្មែរក្រហមភ្លាម ពួកគាត់ហាក់ ពេញចិត្តនឹងនិយាយប្រាប់យើងទាំងអស់គ្មានលាក់លៀមឡើយ ។ លោកតា លី ងៀន អាយុ៨៨ឆ្នាំ រស់នៅ ច័ន្ទអណ្តែត ឃុំទួលទួលសុភី ស្រុកអង្គរជ័យ បាននិយាយថា អ្នកទោសដែល យកមកដាក់ឃុំឃាំងក្នុងមន្ទីរនេះ ភាគច្រើនបំផុតគឺ ជាមនុស្សដែលមានឋានៈជាកម្មាភិបាល និងទាហាន ខ្មែរក្រហម ព្រោះជាគុកភូមិភាគបូព៌ា ។ អ្នកទោសទាំងអស់មិនត្រូវបានរួចខ្លួនពីសេចក្តីស្លាប់ឡើយ ។ លោកតាបន្តថា គុកភូមិភាគនេះបានបង្កើតឡើង តាំងពីឆ្នាំ១៩៧៥មក ហើយមានឃុំឃាំងពួក កម្មាភិបាល និងទាហានខ្មែរក្រហមដែលមានកំហុសក្លងបន្តិច បន្តួចខាងនយោបាយ ។ លោកតា ម៉ៅ ម៉ុន អាយុ៥២ឆ្នាំ បាននិយាយពីបោកបញ្ឆោតកម្មាភិបាល គ្នាឯងមកដាក់គុកថា មានបញ្ជាមួយឲ្យ ហៅពួកកម្មាភិបាលដែលនៅខេត្តព្រៃវែង ខេត្តស្វាយរៀង និងកន្លែង ផ្សេងៗ មករៀនសូត្រនៅ កន្លែងនេះ(ភ្នំដី) ។ លុះមកដល់ភ្នំដីនេះ អ្នកទាំងអស់មិនបានរៀនសូត្រអីទេគឺ ត្រូវយកបញ្ចូលក្នុងមន្ទីរ ឃុំឃាំងទាំងអស់ ។ លោកតាក៏បាននិយាយពីទោសកំហុសរបស់អ្នកមកជាប់ទោសទាំង នោះថា សុទ្ធតែ មានការចោទប្រកាន់ទាំងអស់នូវទោសកំហុសដែលសាម៉ីខ្លួនពុំបានដឹងទាល់តែសោះ ។ មិនថាពួកកម្មា- ភិបាលធំៗទេ សូម្បីតែកូនទាហានតូចតាចក៏យកមកដាក់នៅក្នុងមន្ទីរភ្នំដីនេះដែរ ។ អ្នកទោសទាំងអស់ ត្រូវ ទទួលទណ្ឌកម្មឲ្យលើកដួវមួយខ្សែពីភូមិចូលមកកាន់ទីតាំងមន្ទីរសន្តិសុខភ្នំដី និងក្រៅពីនេះមានឲ្យ ធ្វើការខ្វះទៀត ដូចជាធ្វើជីដាក់ស្រូវជាដើម ។ អំពើទាំងនេះត្រូវបានលោកតាធ្វើការសន្និដ្ឋាន និងនិយាយ ផ្ទាល់មាត់ថា«សកម្មភាព របស់ពួកខ្មែរក្រហមនេះ បានន័យថាវាសម្លាប់ឥតមានពិចារណា គ្មានរក យុត្តិធម៌ឲ្យកម្មាភិបាលដូចគ្នា ក៏ដូចជា រាស្ត្រដទៃទៀត អត់មានរកយុត្តិធម៌ទេ ឲ្យតែខុសដឹងតែរកត្បូង ចបនឹងសម្លាប់» ។ ការឃុំឃាំងនេះមិនត្រូវបាន ដោះលែងឡើយ ។ មានកន្លែងសម្លាប់មួយស្ថិតនៅ ខាងកើតភ្នំដីប្រមាណ៥០ម៉ែត្រប៉ុណ្ណោះ ។ និយាយពីការ ធ្វើទណ្ឌកម្មចំពោះអ្នកទោសវិញ លោកតា លី ងៀន និយាយថា គាត់បានឃើញផ្ទាល់ភ្នែកនូវការធ្វើទណ្ឌកម្ម យ៉ាងសាហាវបំផុត ជួនកាល អ្នកទោសមិនទាន់ស្លាប់ផង ត្រូវពួកខ្មែរក្រហមសែងយកទៅកប់ទាំងរស់ ។ មាន អណ្តូងមួយសម្រាប់ ស្ងួរចម្លើយអ្នកទោសដែលស្ថិតនៅប៉ែកខាងលិចមន្ទីរឃុំឃាំងភ្នំដី ។ លោកតាម៉ៅ ម៉ុនបាន និយាយពី

រឿងនេះប្រាប់ថា នៅគែមសន្ទាងមាត់អណ្តូងមានដាំបង្គោលពីរ ហើយមានបោះដាធ្នឹមសម្រាប់ភ្ជួរជើងអ្នកជើងឡើងលើ សំយ៉ុងក្បាលចុះក្នុងទឹក (បច្ចុប្បន្នអណ្តូងនេះនៅមានស្លាកស្នាមនៅឡើយ) ។ ឯអ្នក ទោសដែលជាប់នៅខាងក្នុងវិញ គឺស្ថិតនៅក្នុងទ្រុងមួយឈរហើយគៀបរើខ្លួនមិនរួច ទាំងយប់ទាំងថ្ងៃឈររហូត ទាល់តែដល់ថ្ងៃដែលត្រូវកម្ទេច ។ ការសម្លាប់មនុស្សមានកើតឡើងជារៀងរាល់ថ្ងៃ ។ លោកពូ ម៉ៅ ម៉ុនបាន អធិប្បាយថា បើអ្នកទោសណាមានទោសធ្ងន់គឺយកមកភ្ជាមសម្លាប់ភ្លាម ដោយមិនបាច់សួរចម្លើយទេ ។ ឯអ្នក ទោសស្រាល ត្រូវឆ្លងកាត់ការសួរចម្លើយជាមុនសិន ។ ការសួរចម្លើយគឺត្រូវផ្តោតសំខាន់ទៅការជជីកសួរពី អ្នកនៅពីក្រោយខ្នងក្នុងការធ្វើការងារក្បត់ ។ យូរៗមានបាញ់គ្នាម្តងរវាងអ្នកទោស និងអ្នកមើលការខុសត្រូវ នៅក្នុងគុក ។ លោកពូ ម៉ៅ ម៉ុនបានរត់ពួនស្ទើរតែរាល់ពេលបាញ់គ្នានេះ ។ ទោះជាមានការប៉ះទង្គិចគ្នាយ៉ាង នេះក៏ដោយ មន្ទីរសន្តិសុខរបស់ភូមិភាគបូព៌ានៅតែបន្តការគ្រប់គ្រងរបស់ខ្លួនរហូតដល់បែកឆ្នាំ១៩៧៩ ។ សមមិត្តតែម ដែលជាអនុប្រធានភូមិភាគបូព៌ា និងជាប្រធានមន្ទីរសន្តិសុខនេះ ត្រូវបានសម្លាប់ដោយគំនុំពី ប្រជាជនក្រោយថ្ងៃជ័យជំនះរបស់រណសិរ្សរំដោះជាតិកម្ពុជា ។ បក្ខពួកមួយចំនួនទៀតរបស់សមមិត្តតែម ត្រូវ បែកខ្ញែក ខ្លះស្លាប់ខ្លះភៀសខ្លួនទៅរស់នៅកន្លែងផ្សេង ។ ឯគុកនេះត្រូវបានរុះរើយកទៅធ្វើផ្ទះសម្បែង ដោយប្រជាជនបានត្រឹមតែបន្សល់ទុកនូវខ្មោះឃ្មៀងជាច្រើនគំនរ ស្លាកស្នាមរណ្តៅជាប់ជើងភ្នំដី រួមជាមួយ ខឿនពិដានខាងក្រោមនៃទីតាំងគុកនេះ និងស្លាកស្នាមអណ្តូងសម្រាប់ភ្ជួរអ្នកទោសសួរចម្លើយ ។ តាមចម្លើយរបស់លោកពូម៉ៅ ម៉ុនបានឲ្យដឹងថាមានរណ្តៅកប់សាកសពច្រើនណាស់រាប់ទាំងរណ្តៅធំពីរ និងរណ្តៅតូចដែលកប់ មនុស្សបានម្នាក់ ឬពីរនាក់ ។ ចំនួនសាកសពទាំងអស់ តាមសម្តីសាក្សីទាំងពីរខាងលើគឺលោកម៉ៅ ម៉ុន និងលោកលី ងៀន ថាមានចំនួនលើសពី៣០០០នាក់ ។

៩) ទីតាំងសម្លាប់ដាយកៅស៊ូ

លេខកូតភូមិសាស្រ្តៈ ០៣១១១២

រយៈកំពស់ **(N) 11º 49' 30:15"**

រយៈទទឹងៈ **(E) 105º 32' 44:23"**

មានអណ្តូងទឹកមួយនៅជាប់នឹងដាយចំការកៅស៊ូលេខ៨៤របស់រដ្ឋ ហើយដែលស្ថិតនៅក្នុងទឹកដីភូមិ ថ្មដាកើត ឃុំទួលសុភី ស្រុកអូរាំងឪ ។ អណ្តូងមួយនេះ ត្រូវបានជីកឡើងកាលពីជំនាន់មុនៗរបបខ្មែរក្រហម បានបង្កើតឡើង ដើម្បីស្តុបទឹកសម្រាប់ធ្វើចំការ ។ ប៉ុន្តែនៅសម័យដែលគ្រប់គ្រងដោយប៉ុលពត អណ្តូងទឹក មួយនេះ ត្រូវបានជ្រើសរើសយកធ្វើជាអណ្តូងសម្រាប់ដាក់សាកសពទៅវិញ ។ ហេតុការណ៍នានាដែលបាន កើតឡើងកាលពីជំនាន់ខ្មែរក្រហមនៅទីតាំងដាយកៅស៊ូ៨៤ មានតែ

មនុស្សពីរនាក់គត់ដែលបានដឹង និងឃើញ ផ្ទាល់ភ្នែក។ លោកពូ សំ សន បានប្រាប់ថា គាត់បានឃើញការសម្លាប់មនុស្សនេះដោយផ្ទាល់ភ្នែក គឺទាញ មនុស្សពីលើឡានមកវៃទំលាក់ចូលក្នុងអណ្តូង។ លោកពូ ហឿន ហន ដែលកាលនោះគាត់មានអាយុ១៥ឆ្នាំ ក៏បានឃើញហេតុការណ៍នេះផ្ទាល់នឹងភ្នែកដែរ។ លោកពូ ហន បានអធិប្បាយនូវដំណើររឿងប្រាប់យើងថា នៅពេលដែលគាត់បានលួចរត់ចេញពីកន្លែងសម្លាប់ឪពុកម្តាយគាត់នៅទួលមនោរម្យមក គាត់បានរត់សំដៅមក កាន់តំបន់ដាយកៅស៊ូនេះ ដែលជាកន្លែងគាត់ធ្លាប់ឃ្វាលក្របី។ ពេលមកដល់ គាត់បានជ្រុលដំណើរចូលដល់ កន្លែងសម្លាប់តែម្តង ហើយបានឃើញពួកកងទព័ខ្មែរក្រហម ដែលលោកពូលើកឡើងថា«សុទ្ធតែពួកនិយាយ រដឺន១» ឈរច្រូងច្រាំងជុំវិញមាត់អណ្តូង។ ពេលនោះពួកទាហានខ្មែរក្រហមបាននិយាយមកកាន់គាត់នូវពាក្យសម្តីរដឹន១ថា «អាវ៉ៃថយបន្តិច បងធ្វើការសិន»។ លោកពូក៏ប្រញាប់ប្រញាល់បកមកក្រោយវិញ ហើយ បានឡើងលើដើមពោធិ៍ដើម្បីលួចមើលព្រឹត្តិការណ៍។ ភាពភ័យតក់ស្លុតរបស់លោកពូបានកើតឡើងភ្លាម ហើយ នឹកឃើញពីការសម្លាប់របស់ពួកខ្មែរក្រហមមកលើឪពុកម្តាយខ្លួននៅមនោរម្យ នៅពេលដែលឃើញការសម្លាប់ មនុស្សទាំងស្រស់ៗបែបនេះ។ ព្រឹត្តិការណ៍សម្លាប់នេះ ត្រូវបានលោកពូរៀបរាប់ថា ពួកខ្មែរក្រហមបានទាញ មនុស្សទំលាក់ពីលើឡានដែលទយជាប់នឹងអណ្តូងស្រាប់ ហើយវាយសំពងពីក្រោយទំលាកចូលក្នុងអណ្តូង។ គាត់បន្តថាមានអ្នកខ្លះ មិនទាន់ងាប់ភ្លាមទេ ប៉ុន្តែនៅពេលដែលធ្លាក់ចូលក្នុងអណ្តូងដែលមានជម្រៅ១៥ម៉ែត្រ បូករួមជាមួយការវាយអ្នកផ្សេង១ទំលាកទៅទៀតគឺត្រូវតែដាច់ខ្យល់ស្លាប់ព្រមគ្នានឹងអ្នកក្រោយដែរ។ ចំពោះ ប្រភេទជនរងគ្រោះដែលយកមកសម្លាប់នៅទីនេះវិញ គឺសុទ្ធសឹង្តតែជាពពួកកម្មាភិបាលរបស់ពួកខ្មែរក្រហម ដែលបានប្រព្រឹត្តិក្បត់នឹងអង្គការគេ។ លោកពូ ហឿន ហន បាននិយាយថា «អ្នកដែលមកស្លាប់នៅទីនេះ គឺ ជាប្រធានកងតូច ប្រធានកងធំ ប្រធានក្រុម ប្រធានភូមិ និងកងចល័តរបស់ពួកគេ»។ ការសម្លាប់ប្រព្រឹត្តិ ទៅនៅម៉ោង៨នឹង៣០នាទីល្ងាច តែក្នុងរយៈពេល១ថ្ងៃគត់។ ពីរថ្ងៃក្រោយមក លោកពូ ហឿន ហនបានទៅមើលកន្លែងសម្លាប់នោះ គាត់បានឃើញក្នុងអណ្តូងមានហើមពេញទៅដោយខ្មោច។ គាត់បន្តថា នៅសល់តែ កំពស់២ម៉ែត្រទៀតប៉ុណ្ណោះ គឺពេញដល់មាត់លើនៃអណ្តូងហើយ។ ចំណែកឯលោកពូ សំ សនវិញគាត់ និយាយថា ក្នុងរយៈពេល១០ថ្ងៃក្រោយពីការសម្លាប់ គាត់បានទៅមើលកន្លែងនោះ ហើយបានឃើញយ៉ាង ច្បាស់នូវសភាពហើមស្អុយរលួយ ពោរពាសចេញពីមាត់អណ្តូងមកក្រៅ។ គាត់និយាយថា «ខ្ញុំបានឃើញ មានឈាមហូរចេញពីមាត់អណ្តូងមកក្រៅ»។ ចំនួនសាកសពនៅក្នុងអណ្តូងនោះ តាមដែលលោកពូទាំងពីរប៉ាន់ ស្មានទៅគឺមានចំនួនពីរ៧០-៨០នាក់។

១០) ទីតាំងសម្លាប់កោះញែក លេខកូតភូមិសាស្ត្រៈ ០៣១១១៣

រយៈកំពស់ (N) 11º 49' 28:95" រយៈទទឹងៈ (E) 105º 32' 50:79"

ទីតាំងសម្លាប់កោះញែក ស្ថិតនៅចម្ងាយប្រហែល៨០០ម៉ែត្រពីទីតាំងសម្លាប់ដាយកៅស៊ូ៨៤ ប៉ែក ខាងកើត។ ទីតាំងនេះស្ថិតនៅប៉ែកខាងជើងឆៀងខាងលិចវត្តថ្មដាប្រហែល៥០០ម៉ែត្រ នៅលើដីដាំសណ្តែក របស់ម្ចាស់ចំការមួយក្នុងភូមិថ្មដាកើត ឃុំទួលសុភី ស្រុកអូរាំងឪ។ តាមរបាយការណ៍ពីការិយាល័យធម្មការ និងសាសនាស្រុកថា មានចំនួន១រណ្តៅ និងចំនួនជនរងគ្រោះ១៦៤នាក់។ ប៉ុន្តែតាមការសាកសួរពត៌មានផ្ទាល់ ពីអ្នកដឹងឮនៅក្នុងភូមិថ្មដាកើតថា មានចំនួន២រណ្តៅ និងចំនួនជនរងគ្រោះពី១៦៤-១៧០នាក់។ លោកតា សំ សន បនច្ចុប្បនដាមេភូមិថ្មដាកើតនិយាយថា “កោះញែកមាន២រណ្តៅ ហើយក្នុងរណ្តៅមួយៗមានទទឹង៣ ម៉ែត្រ បណ្តោយ៥ម៉ែត្រ ជម្រៅ៣ម៉ែត្រ”។ ហេតុការណ៍សម្លាប់តាំងពីដើមដល់ចប់នៅលើទីតាំងកោះញែកត្រូវបានលោកតាឃ្លាំមើលឃើញទាំងអស់នូវសកម្មភាពពិតៗ ហើយត្រូវលោកតាលើកយកមករ៉ាយរ៉ាប់ប្រាប់ថា នៅពេលដែលក្រុមការងាររបស់លោកតាកំពុងបំពេញការងារនៅលើកោះញែកនេះ ស្រាប់តែមានពួកខ្មែរក្រហម មកប្រាប់ថាឲ្យថយចេញពីទីនេះបន្តិចសិន ព្រោះត្រូវមានការធ្វើនៅកន្លែងនេះ។ ឮដូច្នេះប្រជាជនទាំងអស់គ្នា នរណាម្នាក់ហ៊ានជំទាស់ឡើយ។ ផ្ទុយទៅវិញលោកតាបានលួចឡើងលើដើមអំពិលមួយដែលស្ថិតនៅឆ្ងាយបន្តិចពីទីតាំងដើម្បីលបមើលសកម្មភាពដែលហៀបនឹងកើតមាន។ ក្រោយពីប្រជាជនចេញអស់ទៅមួយស្របក់គាត់ បានឃើញមានឡានចិនជាច្រើនដឹកមនុស្សពេញៗមកទយដល់មាត់រណ្តៅដែលបានជីករួចជាស្រេច។ ការងារ បន្ទាប់របស់ពួកខ្មែរក្រហមគឺ វ៉ៃអ្នកទោសដែលបានចងស្លាបសេក និងឃ្លុំមុខរួចជាស្រេចនោះទំលាក់ពីលើឡាន ចូលក្នុងរណ្តៅ។ ការសម្លាប់ចាប់ផ្តើមនៅម៉ោង៣រសៀល។ លោកតាក៏បានបញ្ជាក់ដែរថា ជនដៃដល់ក្នុងការ សម្លាប់មនុស្សនៅកោះញែកគឺមានគ្នាប្រហែល១០នាក់ប្រដាប់ដោយដំបង និងគល់ពីងពង់ជាឧបករណ៍សម្លាប់។ រយៈពេល១០ថ្ងៃក្រោយការសម្លាប់ លោកតាបានទៅឃើញរណ្តៅនៅកោះញែក ហើយបានពិនិត្យឃើញជាក់ ស្តែងនូវសាកសពហើមរលួយ ស្អុយប្រេះដីក្រហមដែលលប់ពីលើយ៉ាងថើរៗ។ នៅលើដីក្រហមនៃរណ្តៅ នោះ គាត់បានសង្កេតឃើញមានដំបង និងគល់ពីងពង់ដែលគាត់បានលបមើលឃើញកាលពីពេលវ៉ៃថ្មីៗនៅយ៉ាង រដូករណែលគរលើគ្នា។ លោកតាក៏បានបញ្ជាក់ប្រាប់ពីខ្មែរក្រហមដៃដល់ទាំងនោះថា គាត់មិនដែលឃើញមុខវ៉ា ទេ ព្រោះពួកនេះជាអ្នកដែលមកពីស្រុកឆ្ងាយៗ។ ក្រោយឆ្នាំ១៩៧៩ រណ្តៅចំនួនពីរត្រូវបានគាស់ឡើង។ គោលបំណងនៃការគាស់ គឺដើម្បីរកមាស និងវត្ថុមានតម្លៃផ្សេងៗដែលជាប់នៅនឹងខ្លួនសាកសព។ ឆ្អឹង

ជា ច្រើនត្រូវបានរើសគេវែងឡើងលើយ៉ាងរបៀត់របៀយ ។ ភាពក្រហេងក្រហូងនៃរណ្តៅមិនត្រូវបានលុបឲ្យដិតវិញឡើយ ។ឆ្អឹងទាំងឡាយត្រូវបាត់ស្រមោលអស់ដោយការបំផ្លាញពីសត្វផ្សេងៗ ។ ស្លាកស្នាមរណ្តៅនៅតែ បង្កួតខ្លួនបញ្ចេញរូបរាងយ៉ាងសង្វាបផ្លាញប្រាប់ពិភពលោកនូវភាពពិតឥតល្អៀងនៃការប្រល័យជីវិតមនុស្ស ស្លូតត្រង់អស់ចំនួន១៧០នាក់តែក្នុងរយៈពេលមួយថ្ងៃប៉ុណ្ណោះនៅលើ ទឹកដីកោះញែកនេះ ។ ព្រលឹងនៃជនរង គ្រោះទាំងនោះនឹងត្រូវហោះហើរគ្មានទីដៅច្បាស់លាស់ ប្រសិនបើការសម្លាប់នេះមិនត្រូវបានរកយុត្តិធម៌ទេ នោះ ។

## ឃុំមៀន

**១១) ទីតាំងសម្លាប់អ្នកតាចាអាង** លេខកូតភូមិសាស្ត្រ ០៣១១១៤

រយៈកំពស់ **(N) 11º 48' 47:47"** រយៈទទឹង **(E) 105º 26' 08:45"**

រោងអ្នកតាចិនមួយកន្លែងត្រូវបានប្រជាជននៅភូមិបឹងកណ្តាល ឃុំមៀន ស្រុកអូរាំងឪ ខេត្តកំពង់ចាម និយមហៅតាំងពីដើមមកថាជា អ្នកតាចាអាង ។ ពេលដែលក្រុមយើងចុះទៅដល់ទីតាំងនេះ យើងសង្កេតឃើញ ក្នុងខ្ទមអ្នកតានោះមានមាន់ស្មោរថ្មី និងមានធូបអុជដែលទំនងជាទើបតែមានអ្នកសែនព្រេនពីរឿងអ្វីមួយ ។ រោងអ្នកតានេះស្ថិតនៅជាប់ជ្រុងខាងលិចឡូតដ្ឋមួយកន្លែង ។ បើយើងធ្វើដំណើរចេញពីសាលាស្រុកអូរាំងឪមក គឺមានចំនួន៧គីឡូម៉ែត្រ ដោយឆ្លងកាត់តាមភូមិថ្មសំលៀង ឃុំមៀន និងឆ្លងកាត់ទីតាំងសម្លាប់មួយទៀតឈ្មោះ បឹងកាពិត ។ នៅក្បែរទីតាំងសម្លាប់អ្នកតាចាអាងប៉ែកខាងត្បូង យើងសង្កេតឃើញមានស្នាមក្រហេងក្រហូង ជាច្រើនកន្លែង ។ តាមពិតជាកន្លែងដែលកម្មករឡូតដ្ឋជីកយកអាចម៍ដីមកធ្វើជាដុំឥដ្ឋ នឹងក្បឿង ប៉ុន្តែក្នុងនោះ ក៏មានរណ្តៅសម្លាប់មនុស្ស១បន្ទំជាមួយផង ។ តាមការបកស្រាយរបស់អ្នកមីង ពិន សុខនថាមានការសម្លាប់មនុស្សដាក់ក្នុងរណ្តៅមួយស្ថិតនៅជាប់នឹងមាត់ស្ទឹងមួយដែលតភ្ជាប់មកពីបឹងការពិត ។ គាត់បានឃើញមនុស្ស ពីរនាក់ត្រូវបានបាញ់សម្លាប់ដោយផ្ទាល់ភ្នែកដោយពួកទាហានខ្មែរក្រហមខាងភូមិភាគនិរតី ។ អ្នកស្លាប់ទាំងពីរ នាក់នោះមានប្រុសម្នាក់ និងស្រីម្នាក់ តាមការអះអាងរបស់អ្នកមីងថា អ្នកទាំងពីរនេះជាខ្មែរក្រហមខាងភូមិ ភាគបូព៌ា ហើយត្រូវបានចោទថាក្បត់ ។ ជនក្បត់ទាំងពីរត្រូវបានបាញ់សម្លាប់ភ្លាមៗនៅនឹងរណ្តៅក្បែររោង អ្នកតាចាអាង ។ ការបាញ់សម្លាប់នេះ គឺក្រោយពេលសម្លាប់រួមមួយដែលធ្វើឡើងដោយទាហានភូមិភាគបូព៌ា មកលើប្រជាជនស្លូតត្រង់មួយចំនួនដែលជាប់គុកនៅវត្តមុនីរង្សី ហៅវត្តកំពុងបឹង ។ ហេតុការណ៍សម្លាប់ជនរង គ្រោះដែលជាប់គុកនៅវត្តកំពុងបឹងនេះ អ្នកមីងពិន

សុខនបានរៀបរាប់ថា មុននឹងយកអ្នកទោសមកសម្លាប់ នៅក្បែរអ្នកតាចារអាងនេះ ជនរងគ្រោះទាំងនោះស្ទើរស្លាប់ស្ទើររស់ទៅហើយ ព្រោះជាប់នៅមន្ទីរសន្តិសុខឯ វត្តកំពុងបឹងនោះ គ្មានបានអ្វីហូបទេ រហូតដល់អ្នកខ្លះយកក្រមាដែលនៅជាប់នឹងខ្លួនហូបអស់ជាងពាក់កណ្ដាល ទៀតផង ។ ទិដ្ឋភាពនៅមន្ទីរសន្តិសុខវត្តកំពុងបឹង គឺយកទីធ្លាវត្តទាំងមូលធ្វើជាបរិវេណសន្តិសុខរបស់ស្រុក ហើយយកសាលារាប់បាត (សាលាឆាន់) ដែលមានចំនួនពីរជាន់ មកធ្វើជាកន្លែងឃុំឃាំង ។ ជាន់ក្រោមច្រើន ឃុំឃាំងប្រភេទអ្នកទោសដែលធ្ងន់ ហើយតម្រូវដាក់ខ្នោះទាំងយប់ទាំងថ្ងៃ ។ ឯជាន់លើនៃសាលាឆាន់ មានឃុំឃាំងប្រភេទមនុស្សដែលមានទោសស្រាល ។ ពួកនេះ អាចបញ្ចេញឲ្យទៅធ្វើការងារជាមួយប្រជាជនធម្មតា បាននៅពេលថ្ងៃ ។ មន្ទីរនេះត្រូវបានបង្កើតឡើងដោយខ្មែរក្រហមខាងភូមិភាគបូព៌ា ហើយត្រូវបំផ្លាញចោល វិញដោយខ្មែរក្រហមខាងភូមិភាគនិរតី ។ តាំងពីពួកនិរតីចូលមកលុកលុយគ្រប់គ្រងខាងបូព៌ា មន្ទីរនេះហាក់ មានភាពរប៉ាត់រប៉ាយ រហូតដល់មានការរុះរើចេញទាំងអស់ ហើយលែងមានការឃុំឃាំងអ្វីទៀតដែរ ។ ប៉ុន្តែ ព្រឹត្តិការណ៍នេះបានកើតឡើងក្រោយការសម្លាប់មនុស្សនៅក្បែររោងអ្នកតាចារអាងទៅហើយ ។ ទោះជាយ៉ាង នេះក៏ដោយ ពួកកម្មាភិបាលខ្មែរក្រហមខាងភូមិភាគបូព៌ាមួយចំនួន ត្រូវបានកម្ទេចចោលនៅលើរណ្ដៅដែលខ្លួន បានកម្ទេចប្រជាជនស្លូតត្រង់កាលពីលើកមុនដោយពួកខ្មែរក្រហមខាងនិរតីវិញដែរ ។ លោកពូសុខ ហេង អាយុ៥៦ឆ្នាំ ជាប្រជាជនរស់នៅភូមិកំពុងបឹង ឃុំមៀន ស្រុកអូររាំងឪ បាននិយាយពីរឿងនេះប្រាប់ថា កន្លែងអ្នកតាចារអាងនេះ មានសម្លាប់មនុស្សស្លូតត្រង់ផង និងមានសម្លាប់មនុស្សដែលធ្លាប់ជាឃាតករផង ។ រឿងនេះដូចអ្នកមីងពិនសុខននិយាយថា ជាការចោទប្រកាន់គ្នាឯងថាក្បត់នឹងអង្គការបក្ស ។ លោកពូ សុខ ហេងនិយាយបន្តបញ្ជាក់ថា គាត់បានឃើញព្រឹត្តិការណ៍សម្លាប់គណៈឃុំពីររូបដែលជាកម្មាភិបាលខ្មែរក្រហមខាង បូព៌ាដោយផ្ទាល់នឹងភ្នែក ។ ដំបូងឡើយ ឃើញសម្លាប់គណៈឃុំជាស្រីនោះមុនគេ ដោយយកឈើ និងចុងកាំភ្លើងទៅរុកចំទ្វារមាសរបស់ស្ត្រីគណៈឃុំនោះ រួចអូសចុះឡើងពីកន្លែងនោ រួចទើបបានពួកខាងនិរតីសម្រេច ចិត្តបាញ់ចំទ្វារមាសនោះជាច្រើនគ្រាប់រហូតដល់ស្លាប់បាត់ទៅ ។ បន្ទាប់មកបានបាញ់រះទៅលើម្នាក់ទៀត ។ លោកពូបានប្រាប់ពីចំនួនជនរងគ្រោះដែលបានស្លាប់នៅក្នុងរណ្ដៅជិតអ្នកតាចារអាងថាមានចំនួនពីរ៥០-៦០ នាក់ដាក់តែក្នុងមួយរណ្ដៅប៉ុណ្ណោះ ។ គាត់ថា ក្រោយព្រឹត្តិការណ៍ប៉ុន្មានថ្ងៃ គាត់បានដើរមកមើល ក៏ឃើញ សាកសពទាំងមុនទាំងក្រោយហើមពេញ ហើយស្អុយទៀត ។

សន្និដ្ឋាន

ការសម្លាប់មនុស្សនៅក្បែររោងអ្នកតាចាអាងនេះ គឺមានសម្លាប់ទាំងប្រជាជនស្លូតត្រង់ និងពួកកម្មាភិបាលខ្មែរ ក្រហមដូចគ្នា បន្ទាប់ពីមានការរីករាលដោយគណៈភូមភាគបូព៌ាក្បត់នឹងបដិវត្តន៍ ។ ជនរងគ្រោះដែលបានស្លាប់ មានចំនួនពី៥០ - ៦០នាក់ ហើយមានតែ១រណ្ដៅទេ ។

## ឃុំអំពិលតាពក

១២) ទីតាំងសម្លាប់ព-២ — លេខកូតភូមិសាស្ត្រ: ០៣១១១៥/១៦

រយៈកំពស់ **(N) 11º 49' 43:40"** — រយៈទទឹង: **(E) 105º 31' 17:76"**

**(N) 11º 50' 14:77"** — **(E) 105º 31' 24:41"**

ទីតាំងសម្លាប់ព-២ជាអតីតមន្ទីរពេទ្យយោធារបស់ភូមិភាគបូព៌ាកាលពីអំឡុងឆ្នាំ១៩៧៥ - ៧៧ ។ បច្ចុប្បន្នទីតាំងនេះស្ថិតនៅខាងជើងសាលាហ៊ីកហ៊ីនយោធាស្រុកអូររាំងឪ ដែលស្ថិតក្នុងភូមិជ្រៃតាសូ ឃុំអំពិល តាពក ស្រុកអូររាំងឪ ។ ចាប់ពីចុងឆ្នាំ១៩៧៧រហូតដល់ចុងឆ្នាំ១៩៧៨ ទីតាំងព-២ បានក្លាយទៅជាទីតាំង សម្លាប់មនុស្សយ៉ាងសាហាវមួយនៅក្នុងស្រុកអូររាំងឪ ។ មូលហេតុនៃការសម្លាប់មនុស្សយ៉ាងសាហាវបែបនេះ ត្រូវបានលោកអ៊ុំប៊ុល ពិន អាយុ៦១ឆ្នាំ ជាអតីតកម្មាភិបាលខ្មែរក្រហមកាន់កាប់ខាងកសិកម្មនិយាយរៀប រាប់ថា មានការបែកបាក់ផ្ទៃក្នុងរវាងកម្មាភិបាលខាងភូមិភាគបូព៌ា និងនិរតី ។ សោភឹម ត្រូវបានតាមរកចាប់ ខ្លួន តាមបញ្ជារអង្គការពីបទក្បត់ចូលដៃជាមួយយួន ។ ទាហានក្រោមបង្គាប់ ត្រូវចាប់យកមកសម្លាប់ជាបន្ត បន្ទាប់នៅព-២ ដោយទាហានខាងភូមិភាគនិរតីដែលមានតាម៉ុកជាប្រធានភូមិភាគ ។ លោកអ៊ុំនិយាយបន្តថា ពួកកម្មាភិបាលខាងសោភឹម ត្រូវបានភៀសខ្លួនជាបន្តបន្ទាប់ចូលព្រៃ បន្ទាប់ពីមានការគំរាមកំហែងជាញឹកញាប់ ពីពួកនិរតី ។ សូម្បីតែគាត់ដែលជាកម្មាភិបាលតូចតាចខាងកសិកម្មក៏ត្រូវភៀសខ្លួនចូលព្រៃដែរ ដោយខ្លាចការ តាមសម្លាប់នេះ ។ គាត់បានបន្តថា ពួកកម្មាភិបាលខាងបូព៌ាដូចគាត់ ត្រូវស្លាប់ទាំងអស់ដោយចាញ់ឃោសនា របស់ពួកខាងនិរតីថា ពួកគេ(និរតី) មិនធ្វើអ្វីចំពោះកម្មាភិបាលខាងបូព៌ាទេ ប្រសិនបើពួក អ្នកទាំងនោះវិលពីព្រៃ មកចូលក្នុងអង្គភាពវិញ ។ នៅសល់តែកម្មាភិបាលពីររូបប៉ុណ្ណោះដែលនៅរស់ ក្នុងនោះមានលោកអ៊ុំប៊ុល ពិន មួយដែរ ។ គាត់និយាយថា គាត់មិនបានចូលមកតាមការឃោសនារបស់ពួកនិរតីទេ ព្រោះគាត់មិនជឿ ។ ហើយម្យ៉ាងទៀតរឿងរ៉ាវដែលគាត់រត់ចូលព្រៃនេះបានកើតមានមុនការលុកលុយចូលមកពីពួកនិរតី ។ គាត់ បាននិយាយរឿងនេះថា គាត់បានមានទំនាស់ជាមួយគណៈតំបន់ពីរឿងស្បៀងអាហារសម្រាប់ប្រជាជនដែល ហូមមានការខ្វះខាត ហើយថ្នាក់លើ។

មាន ម្ហូបអាហារបរិបូរណ៍ ។ គាត់និយាយថា ធ្វើរបៀបនេះគឺជួយទាំងស្រុង ទៅនឹងការរៀនសូត្រដែលគាត់បានរៀនក្នុងសៀវភៅទស្សនាវដ្ដី«ទង់បដិវត្តន៍លេខ១១» ។ គាត់ត្រូវបានតាម រកចាប់ខ្លួនពីគណៈតំបន់រហូតដល់មន្ទីររបស់គាត់ ។ ប៉ុន្តែការចាប់ខ្លួនគាត់មិនទាន់បានផង ត្រូវពួកនិរតីចូលមក កាន់កាប់ជំនួសបន្ទាប់ពីមានការឃោសនាថា «សោភឹមប្រធានភូមិភាគបូព៌ាបានក្បត់នឹងបដិវត្តន៍ហើយ» ។ គណៈតំបន់នោះត្រូវចាប់ខ្លួនមកសម្លាប់នៅព-២ ឯគាត់ក៏បានរួចខ្លួនពីការតាមចាប់ ហើយបន្តនៅក្នុងព្រៃតទៅទៀតសំងំលាក់ខ្លួនតទៅទៀត ដោយលាក់ប្រវត្តិរបស់ខ្លួនដែលជាកម្មាភិបាលខាងបូព៌ា ។ សោភឹមបានធ្វើអត្តឃាដ ដោយខ្លួនឯងព្រោះដឹងថាមិនអាចយកឈ្នះបាន កូនចៅទាំងអស់របស់សោភឹមនៅក្នុងស្រុកអូរាំងឪដែលពីមុន ធ្លាប់បានធ្វើបាប និងសម្លាប់ប្រជាជនស្លូតត្រង់ដោយការចោទប្រកាន់នានាត្រូវបានសម្លាប់ទាំងអស់នៅចុងឆ្នាំ ១៩៧៨ ឯចំការកៅស៊ូក្បែរមន្ទីរព-២ ដែលពីមុនធ្លាប់តែមានកម្មករ ដៀរជ័រកៅស៊ូពេញៗនោះ ។ កម្មករ ទាំងអស់ត្រូវបានបណ្ដេញចេញ ។ អណ្ដូងទឹកចំនួនពីរក្នុងដីចំការកៅស៊ូតាឈៀនត្រូវបានជ្រើសរើសជាទីតាំងសម្លាប់មនុស្ស ។ ការសម្លាប់មនុស្សនៅព-២នេះត្រូវលាតត្រដាងការពិតប្រាប់យើងដោយលោក ប៉ិល ពិនថា មានសម្លាប់ទាំងចាស់ទាំងក្មេង មានទាំងទាហានដែលដេកព្យាបាលនៅក្នុងមន្ទីរពេទ្យ មានប្រជាជនស្លូត ត្រង់ និងមានទាំងពួកកម្មាភិបាលខាងភូមិភាគបូព៌ាជាច្រើននាក់ផង ។ ជនរងគ្រោះដែលត្រូវយកមកសម្លាប់ ច្រើនជាងគេគឺយកមកពីឃុំចកឃុំដំរិល និងឃុំអំពិលតាពក ។ លោកប៉ិល ពិនបានបញ្ជាក់ថា សូម្បីតែទាហាន ដែលចាប់បានក្នុងសង្គ្រាម ហើយបានបញ្ជូនមកដាក់នៅវត្តព្រះធាតុកាលពីឆ្នាំ១៩៧៥នោះ ក៏យកមកសម្លាប់ នៅព-២នេះដែរ ។ ចំណែកឯប្រពន្ធ កូន ព្រមទាំងសាច់ញាតិរបស់ពួកទាហានទាំងនោះត្រូវសម្លាប់ទាំងអស់នៅក្នុងអណ្ដូងតាស៊ាន ។ មានឡានជាច្រើនបានដឹកអ្នកទោសយកមកសម្លាប់ ។ អ្នកឃើញហេតុការណ៍ផ្ទាល់ភ្នែកដូចលោកអ៊ុំ ប៉ិល ពិនស្ទើរតែមិនជឿនូវហេតុការណ៍ដែលបានកើតឡើងនេះទាល់តែសោះ ។ គាត់និយាយថា ពួក អ្នកសម្លាប់គឺមានវ័យក្មេងៗ និយាយរដឺនៗស្ទើរស្ដាប់មិនបាន ។ អណ្ដូងចំនួនពីរនៅលើទឹកដីចម្ការកៅស៊ូដែល បច្ចុប្បន្នមានឈ្មោះឈួន ឡាយជាម្ចាស់ដីនោះ ពោរពេញទៅដោយសាកសព ហើមស្អុយរលួយស្ទើរចូលទៅជិត មិនបាន ។ ក្រោយរំដោះឆ្នាំ១៩៧៩ អណ្ដូងទាំងពីរនេះត្រូវបានគាស់កកាយ ។ ឆ្អឹងនិងលលាដ៏ក្បាលជាច្រើន ត្រូវបានលើកចេញមកគរនៅខាងក្រៅអណ្ដូង ។ លោកអ៊ុំ មឿង ហ៊ិន អាយុ៦១ឆ្នាំ រស់នៅឃុំអំពិលតាពក ស្រុកអូរាំងឪ បាននិយាយថា គាត់ស្ទើរតែមិនជឿឡើយនូវចំនួនមនុស្សស្លាប់ច្រើនយ៉ាងនេះសោះនៅទីតាំង ព-២នេះ ព្រោះកាលពីគាត់មិនទាន់រត់ចូលព្រៃ ទីតាំងនេះនៅជាមន្ទីរពេទ្យទាហាននៅឡើយទេ ។ លោកអ៊ុំបន្ត ថាគ្រាន់តែឆ្អឹងដែលដឹកយកទៅ(មិនដឹងយកទៅកាន់ទីណា) មានចំនួនច្រើនរទេះ(រទេះគោ) ណាស់ ឯលលាដ៏ ក្បាលក៏

ច្រើនដូចគ្នា ។ គាត់និយាយថា នៅពេលដែលគាស់នោះ គាត់សង្កេតឃើញមានសម្លៀកបំពាក់ទាហាន ជាច្រើនកំប្លែដែលមិនទាន់រលួយ ។ លោកអ៊ឹបានធ្វើការសន្និដ្ឋានថា ក្នុងអណ្តូងទាំងពីរនេះ មានចំនួន សាកសព រាប់ពាន់នាក់ ព្រោះយោងតាមការឃើញផ្ទាល់ភ្នែកនូវការជីកឆ្អឹងចេញរាប់រទេះ និងតាម ប្រភេទនៃអណ្តូងទាំង ពីរផង ។ អណ្តូងទាំងពីរនេះ មានទំហំមួយៗគឺជាង១០ម៉ែត្របួនជ្រុង និងជម្រៅ ១២ម៉ែត្រ ។ លោកពូ ពេញ ជឹម អាយុ៥៦ឆ្នាំ ជាជំទប់លេខ១ឃុំអំពិលតាពក បាននិយាយថា ការ យកប្រជាជន និងកម្មាភិបាលខ្មែរ ក្រហមខាងបូព៌ាមកសម្លាប់នៅព-២នេះគឺមានចំនួន២២៥៨នាក់ ។ គាត់បានលើកអំណះអំណាងថា គាត់ជា អ្នកដែលមកជីក ហើយបានរាប់ចំនួនដើម្បីធ្វើស្ថិតិកាលពីឆ្នាំ ១៩៨១-៨២ ។

អណ្តូងទាំងពីរនេះស្ថិតនៅចម្ងាយប្រហែល១២០០-១៣០០ម៉ែត្រពីគ្នា ។ ក្នុងការកំណត់យក ចំនុចរយៈកំពស់និងរយៈទទឹងនៃកូអ័រដោនេភូមិសាស្រ្ត ក្រុមដែនទីយើងបានកំណត់យកចំណុចពីរព្រោះ កាឃ្លាត គ្នាពីរណ្តៅមួយទៅមួយ គឺមានចំនួនឆ្ងាយពីគ្នាពេក ។ ទីតាំងព-២តែមួយ ប៉ុន្តែមានការ បំបែកជាពីរគឺ ទីតាំង សម្លាប់ព-២ (១) និងទីតាំងសម្លាប់ព-២ (២) ។

## សន្និដ្ឋានរួម

ចុងឆ្នាំ១៩៧៨ នៅស្រុកអូរាំងឪមានការសម្លាប់មនុស្សយ៉ាងសាហាវមួយបានកើតឡើងហាក់ ដូចជា មានការចងគំនុំនឹងគ្នាពីកាលណាមកអញ្ចឹង ។ ពួកទាហានខ្មែរក្រហមខាងភូមិភាគបូព៌ាបានកាប់ សម្លាប់មនុស្សដែល ជាប្រជាជនស្លូតត្រង់ក្នុងឡេសមួយតាមតែការចោទប្រកាន់ ។ ក្រោយមកទៀត មានពួកនិរតីមកគ្រប់គ្រងបន្ត ពីលើពួកបូព៌ា ហើយយកមនុស្សដែលជាកម្មាភិបាលខាងបូព៌ាយកទៅ សម្លាប់វិញម្តង បូករួមទាំងជីវិតប្រជាជន ស្លូតត្រង់ដែលមិនដឹងអីទាល់តែសោះផង ។ ប្រជាជនខ្លះបាន នាំគ្នារត់ចូលព្រៃដើម្បីងើបឡើងតស៊ូនឹងរបបផ្តាច់ ការទាំងនេះ ។ ចំណែកមនុស្សភាគច្រើនទៀត ត្រូវ ស្លាប់ស្ទើរផុតពូជក្រោមស្នាដៃកសាងបដិវត្តន៍សង្គមនិយម ដ៏មហាអស្ចារ្យរបស់ប៉ុលពត ដែលមានអ្នក ធ្វើគ្រាប់តាមឥតខ្ចោះ តាម៉ុក ជាអ្នកអនុវត្តនូវបញ្ជាដែលដាក់ចុះ ។ ទីតាំងទាំងប៉ុន្មានខាងលើដែលបាន អធិប្បាយមកនេះ បង្ហាញយ៉ាងច្បាស់ក្រៃលែងអំពីការកាប់សម្លាប់ប្រជាជន ដោយឥតញញើតដៃ ពីពួកនិរតី ។ ជនរងគ្រោះទាំងឡាយបានរស់ក្នុងសភាពភ័យខ្លាចអស់រយៈពេលជាងបីឆ្នាំ ក្រោមការ ត្រួតត្រាពីរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានប៉ុលពត ឬសាឡុត ស ជាគណៈមជ្ឈឹមបក្ស ។ ក្នុង កិច្ចសម្ភាសន៍ទាំងឡាយដែលបានសម្ភាសន៍ សុទ្ធតែបានបញ្ជាក់យ៉ាងច្បាស់ពីការបំផ្លាញវត្តអារ៉ាម ផ្សែក

ព្រះសង្ឃតាមវិន័យរបស់អង្គការ ធ្វើទារុណកម្មគ្រប់បែបគ្រប់យ៉ាងទាំងកម្លាំងកាយ កម្លាំងចិត្ត បូករួមទាំងការ បោកបញ្ឆោតនានាក្នុងការយកមនុស្សទៅសម្លាប់ចោល ។ សាក្សីគ្រប់រូបដែលបានសម្ភាសន៍ សុទ្ធតែប្រាថ្នាសុំ កុំឲ្យជួបរបបដែលមានតែការបំផ្លាញជីវិតមនុស្សបែបនេះទៀត ហើយសុទ្ធតែបាននិយាយ គ្រប់មាត់ថា ជីវិត ប្រជាជនកម្ពុជានឹងអស់ពីលើទឹកដីកម្ពុជា ប្រសិនណារបបនេះ(កម្ពុជាប្រជាធិបតេយ្យ) នៅតែបន្តរហូតដល់ ទសវត្សរ៍ទី៨០ ទៀត ។